# របាយការណ៍ប្រចាំឆ្នាំ ២០១៩

គិតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

## ធនាគារវឌ្ឍនៈអាស៊ីចំកាត់

(ធនាគារ ABA)

# ទស្សនៈវិស្ស័យ

ចក្ខុវិស័យរបស់ធនាគារ គឺដើម្បីក្លាយជាធនាគារលំដាប់លេខ១ប្រចាំប្រទេសលើផ្នែកផ្គត់ផ្គង់សេវាធនាគារដែលអាចពឹងពាក់បាន, ងាយស្រួលប្រើប្រាស់, មានបច្ចេកវិទ្យាទំនើបឈានមុខ, និងងាយស្រួលក្នុងការទៅទទួលយក។ យើងមានបំណងក្លាយជាធនាគារមួយដែលប្រជាពលរដ្ឋកម្ពុជាជឿទុកចិត្តក្នុងការបំពេញតម្រូវការសេវាធនាគារសម្រាប់រូបវន្តបុគ្គល និងសម្រាប់អាជីវកម្ម។

# បេសកកម្ម

បេសកកម្មរបស់យើង គឺដើម្បីជួយដល់ប្រទេសកម្ពុជា, អាជីវកម្មកម្ពុជា, និងពលរដ្ឋកម្ពុជាក្នុងការកសាងអនាគតកាន់តែទូលំទូលាយ និងត្រចះត្រចង់សម្រាប់ខ្លួន និងប្រទេសជាតិតាមរយៈការផ្តល់សេវាធនាគារប្រកបដោយជំនាញវិជ្ជាជីវៈខ្ពស់ និងបច្ចេកវិទ្យាទំនើបបំផុតក្នុងវិស័យធនាគារសម្រាប់ទាំងអស់គ្នា។

យើងចាត់ទុកខ្លួនឯងថាជាដៃគូដ៏ល្អមួយសម្រាប់សហគមន៍កម្ពុជាក៏ដូចជាអាជីវកម្មឯកជន និងរូបវន្តបុគ្គលផងដែរ។ យើងនៅទីនេះ ដើម្បីបម្រើសេវាកម្មជូនប្រទេសកម្ពុជា។

# គុណតម្លៃ

គុណតម្លៃរបស់យើងបានបង្កើតជាគ្រឹះដ៏សំខាន់សម្រាប់អាជីវកម្មរបស់យើង។ យើងជឿជាក់លើសារៈសំខាន់នៃ៖

### សុចរិតភាព និងសេចក្តីគោរព

នៅធនាគារ ABA យើងចាត់ទុកចំណុចនេះជាការទទួលខុសត្រូវខ្ពស់របស់ធនាគារដែលត្រូវបម្រើសេវាជូនរាល់អតិថិជនប្រកបដោយភាពសុចរិត និងសេចក្តីគោរព។ដោយអនុវត្តតាមគុណតម្លៃនេះដោយហ្មត់ចត់ យើងទទួលបានការគោរព និងទំនុកចិត្តពីអតិថិជនរបស់យើងវិញ។

### និរន្តរភាព និងកំណើន

នៅធនាគារ ABA យើងតែងតែគិតគូរអំពីអនាគតរបស់ធនាគារយើង និងប្រជាជនកម្ពុជា ព្រមទាំងប្រទេសកម្ពុជាផងដែរ។ យើងសូមបង្ហាញនូវការប្តេជ្ញាចិត្តដ៏មោះមុតដូចគ្នាចំពោះបុគ្គលិករបស់យើង ក៏ដូចជាអតិថិជនរបស់យើងផងដែរ។ នេះ គឺជាវិធីសាស្រ្តមួយដែលអាចឲ្យយើងធានាបាននូវកំណើនប្រកបដោយនិរន្តរភាពរបស់ធនាគារ។

### ក្រមសីលធម៌ និងសុជីវធម៌

នៅ ABA យើងអនុវត្តស្តង់ដារក្រមសីលធម៌ និងសុជីវធម៌រវាងគ្នានឹងគ្នា ពោលគឺទាំងនៅក្នុង និងក្រៅធនាគារ។ គោលការណ៍ផ្ទាល់ខ្លួននេះហើយដែលបង្កើតបានជាមូលដ្ឋានគ្រឹះសម្រាប់ទំនាក់ទំនងប្រចាំថ្ងៃ ជាមួយអតិថិជន និងសហគមន៍ដែលយើងកំពុងផ្តល់សេវាជូន ក៏ដូចជាជាមួយបុគ្គលិករបស់យើងផងដែរ។

### ទំនុកចិត្ត និងភាពជាដៃគូ

នៅធនាគារ ABA យើងនៅទីនេះដើម្បីជួយសម្រួល និងជាជំនួយការរបស់អតិថិជន។ យើងខិតខំធ្វើឲ្យខ្លួនក្លាយជាដៃគូដ៏ល្អដែលអតិថិជនរបស់យើងអាចជឿទុកចិត្តបាន។

### វិភាគទាន

នៅធនាគារ ABA យើងមានគោលបំណងផ្តល់វិភាគទានជាវិជ្ជមានដល់ប្រទេសកម្ពុជា។ យើងចង់ដើរតួនាទីមួយដែលផ្តល់សារប្រយោជន៍សម្រាប់ការរស់នៅរបស់អតិថិជនយើង

ក៏ដូចជាសកម្មភាពនានាដែលរួមចំណែកនាំមកនូវអនាគតដ៏ល្អប្រសើរដល់ប្រទេសជាតិទាំងមូលផងដែរ។

### គុណភាពនៃសេវាកម្ម

នៅធនាគារ ABA យើងខិតខំស្វែងរកដំណោះស្រាយដើម្បីឆ្លើយតបចំពោះរាល់តម្រូវការសេវាធនាគារទាំងអស់។ យើងមានបំណងផ្តល់សេវាកម្មធនាគារប្រកបដោយទំនុកចិត្ត និងមានបច្ចេកវិទ្យាទំនើបបំផុតសម្រាប់អតិថិជនកម្ពុជាទាំងអស់របស់យើង ពោលគឺក្នុងតួនាទីជាជំនួយការគ្រប់គ្រងគណនីផ្ទាល់ខ្លួន ឬគណនីអាជីវកម្មរបស់អតិថិជន។

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| បរិយាយ | ២០១៩ | ២០១៨ |
|---|---|---|
| **ស្ថានភាពហិរញ្ញវត្ថុ (លានរៀល)** | | |
| ទ្រព្យសកម្មសរុប | ១៧.៩០៩.១៧០ | ១១.០២០.៥០៣ |
| បំណុលសរុប | ១៥.៨៨៦.៤២១ | ៩.៧៣៨.៨៨៧ |
| មូលធនសរុប | ២.០២២.៧៤៩ | ១.២៨១.៦១៧ |
| **លទ្ធផលហិរញ្ញវត្ថុ (លានរៀល)** | | |
| ចំណូលសរុប | ១.២៤៣.៥៣៧ | ៨៥៩.៧៨៣ |
| ចំណេញ/(ខាត)មុនបង់ពន្ធ | ៥៧៦.៩៩៧ | ៣៧៦.៧២៥ |
| ចំណេញសុទ្ធ/(ខាត)មុនបង់ពន្ធ | ៥១៦.៦៥៣ | ៣០០.០២៩ |
| ចំណេញសុទ្ធ/(ខាត)ក្នុងការិយបរិច្ឆេទ | ៥២៦.៧៦៧ | ២៩៦.៨៦០ |
| **អនុបាតហិរញ្ញវត្ថុ (%)** | | |
| អនុបាតសោធនភាព[១] | ១៩,៩៤ | ១៩,៩៥ |
| អនុបាតបំណុលធៀបនឹងមូលធន | ៧៨៥,៣៩ | ៧៥៩,៨៩ |
| អនុបាតសន្ទនីយភាព | ១៦២,៣២ | ១៣២,៥១ |
| អនុបាតឥណទានមិនដំណើរការ | ០,៧០ | ០,៧៨ |
| អនុបាតបញ្ញើឥណទាន | ៨១,៤២ | ៨៣,៩១ |
| **អនុបាតផលចំណេញ (%)** | | |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម | ៣,៥៧ | ៣,៣៧ |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម | ៣១,២៧ | ២៨,៣៣ |
| អនុបាតលទ្ធភាពបង់ការប្រាក់ | ៣៧៩,០៨ | ២៩៣,១៥ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | គ្មាន | គ្មាន |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត (ប្រសិនមាន) | គ្មាន | គ្មាន |

[១] នាថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៩ ធនាគារវឌ្ឍនៈអាស៊ីចំកាត់ បានធ្វើការស្នើសុំទៅធនាគារជាតិនៃកម្ពុជា ដើម្បីបញ្ចូលដើមទុនបន្ថែមចំនួន ១២០ លានដុល្លារអាមេរិក ស្មើនឹង ៤៨០ ពាន់លានរៀល និងបានទទួលលិខិតយល់ព្រម ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៩ ពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី ២ ខែមករា ឆ្នាំ២០២០។ បន្ទាប់ពីទទួលបានលិខិតយល់ព្រម ធនាគារជាតិនៃកាណាដាបានបញ្ចូលដើមទុននៅថ្ងៃតែមួយ ដែលជំរុញឱ្យអនុបាតសោធនភាពរបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ កើនឡើងដល់ ២១,១១% នៅថ្ងៃទី ២ ខែមករា ឆ្នាំ២០២០។

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប

## ទ្រព្យសកម្មសរុប

គិតជាលានរៀល

៦២,៥%

កើនឡើងពីឆ្នាំ ២០១៨

១៧.៩០៩.១៧០
ឆ្នាំ២០១៩

១១.០២០.៥០៣
ឆ្នាំ ២០១៨

## បំណុលសរុប

គិតជាលានរៀល

៦៣,១%

កើនឡើងពីឆ្នាំ ២០១៨

១៥.៨៨៦.៤២១
ឆ្នាំ២០១៩

៩.៧៣៨.៨៨៧
ឆ្នាំ ២០១៨

## មូលធនសរុប

គិតជាលានរៀល

៥៧,៨%

កើនឡើងពីឆ្នាំ ២០១៨

២.០២២.៧៤៩
ឆ្នាំ២០១៩

១.២៨១.៦១៧
ឆ្នាំ ២០១៨

## លទ្ធផលលម្អិតក្នុង ការិយបរិច្ឆេទ

គិតជាលានរៀល

៧៧,៤%

កើនឡើងពីឆ្នាំ ២០១៨

៥២៦.៧៦៧
ឆ្នាំ២០១៩

២៩៦.៨៦០
ឆ្នាំ ២០១៨

## អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម

គិតជាភាគរយ

៥,៩%

កើនឡើងពីឆ្នាំ ២០១៨

៣,៥៧
ឆ្នាំ២០១៩

៣,៣៧
ឆ្នាំ ២០១៨

## អនុបាតចំណេញធៀបនឹងមូលធនមធ្យម

គិតជាភាគរយ

១០,៤%

កើនឡើងពីឆ្នាំ ២០១៨

៣១,២៧
ឆ្នាំ២០១៩

២៨,៣៣
ឆ្នាំ ២០១៨

# សមាសភាពក្រុមប្រឹក្សាភិបាល



**Yves Jacquot**
ប្រធានក្រុមប្រឹក្សាភិបាល



**Dominic Jacques**
អភិបាលមិនប្រតិបត្តិ



**Madi Akmambet**
អភិបាលប្រតិបត្តិ



**Martin Ouellet**
អភិបាលមិនប្រតិបត្តិ



**Lionel Pimpin**
អភិបាលមិនប្រតិបត្តិ



**Christian St-Arnaud**
អភិបាលមិនប្រតិបត្តិ



**Guy Quaden**
អភិបាលឯករាជ្យ



**Henri Calvet**
អភិបាលឯករាជ្យ



**Etienne Chenevier**
អភិបាលឯករាជ្យ

# សាររបស់ប្រធានក្រុមប្រឹក្សាភិបាល

ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយសូមជម្រាបជូន អំពីលទ្ធផលប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារ ABA ក្នុងឆ្នាំ២០១៩ ស្របទៅតាមលក្ខខណ្ឌកំណត់របស់គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក)។

ធនាគារ ABA ជាថ្មីម្តងទៀត បង្ហាញពីកំណើនដ៏រឹងមាំលើគ្រប់ប៉ារ៉ាម៉ែត្រទាំងអស់ ដែលរួមមានទ្រព្យសកម្មសរុប ប្រាក់បញ្ញើ និងឥណទាន ក៏ដូចជា មូលដ្ឋានអតិថិជនផងដែរ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ទ្រព្យសកម្មសរុបកើនបាន ៦០% ស្មើនឹង ៤,៣៩ ប៊ីលានដុល្លារអាមេរិក ធៀបទៅនឹងដំណាច់ឆ្នាំ២០១៨ ខណៈពេលដែលផលបត្របញ្ញើ កើនបាន ៥៥% មានតម្លៃស្មើនឹង ៣,៤០ ប៊ីលានដុល្លារអាមេរិក ហើយផលបត្រឥណទាន កើនដល់ ២,៧៦ ប៊ីលានដុល្លាអាមេរិក ដែលគិតជាភាគរយគឺ ៥០% ចាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

មូលធនរបស់ភាគហ៊ុនិកនៃធនាគារ ក៏កើនឡើងផងដែរ ដោយសម្រេចបាន ៤៩៦លានដុល្លារអាមេរិក ក្នុងអំឡុងពេលនៃរបាយការណ៍នេះ។ ធនាគារជាតិកាណាដា ដែលជាភាគហ៊ុនិក បានបង្ហាញពីការប្តេជ្ញាចិត្តដោយដាក់បន្ថែមទុនចំនួន ១២០លានដុល្លារអាមេរិក ដែលដំណើរការនឹងត្រូវបញ្ចប់រួចរាល់ក្នុងខែមករា ឆ្នាំ២០២០។ ការដាក់ទុនបន្ថែមនេះ ទទួលបានការអនុម័តពីធនាគារជាតិនៃកម្ពុជា នៅក្នុងខែធ្នូ ឆ្នាំ២០១៩។ ចំណែកទុនបន្ថែមនេះ នឹងជួយគាំទ្រដល់កំណើនបន្ថែមរបស់ធនាគារ ដោយរក្សាបានអនុបាតសាធនភាព ជាមួយកិច្ចប្រតិបត្តិតាមពេញលេញដែលតបតាមលក្ខខណ្ឌតម្រូវផ្នែកនិយ័តកម្ម ឬបញ្ញត្តិច្បាប់។

ABA ជានាបានប្រាក់ចំណេញសុទ្ធដ៏រឹងមាំចំនួន ១២៧,៤១លានដុល្លារអាមេរិក សម្រាប់មួយឆ្នាំពេញ នៃឆ្នាំហិរញ្ញវត្ថុ ២០១៩។ ធនាគារយើងខ្ញុំ នៅតែនាំមុខគេផ្នែកផលចំណេញ ដោយមានអនុបាត ROAE (អនុបាតចំណេញធៀបនឹងមូលធនមធ្យម) ៣១,៣% គិតត្រឹមដំណាច់ត្រីមាសទី៤ ឆ្នាំ២០១៩។

ក្នុងទិដ្ឋភាពទូទៅ ធនាគារ ABA នៅតែបន្តដោយជោគជ័យក្នុងការអនុវត្តយុទ្ធសាស្ត្រធុរកិច្ចរបស់ខ្លួនដោយផ្តោតលើផលិតផលហិរញ្ញវត្ថុឌីជីថល ក៏ដូចជាឥណទានប្រកបដោយផលិតភាពដល់អាជីវកម្មដែលស្ថិតនៅក្នុងវិស័យពិតនៃសេដ្ឋកិច្ច។ ធនាគារ ABA កំពុងអនុវត្តវប្បធម៌គ្រប់គ្រងហានិភ័យដ៏រឹងមាំ ដែលត្រូវបានពង្រឹងដោយសវនកម្ម និងកិច្ចការប្រតិបត្តិតាមពេញលេញលើគ្រប់សកម្មភាពធុរកិច្ចរបស់ខ្លួន។

ក្នុងអំឡុងរបាយការណ៍ ធនាគារ ABA សម្រេចបានជំហានជោគជ័យគួរឲ្យកត់សម្គាល់ជាច្រើន ដែលបើកទំព័រប្រវត្តិសាស្ត្រថ្មីរបស់ខ្លួន។ នៅក្នុងខែតុលា ធនាគារជាតិកាណាដាបានទិញយកភាគហ៊ុនចុងក្រោយរបស់ ABA ដោយឥឡូវនេះកាន់កាប់ភាគហ៊ុនសរុប ៩៩,៩៩%។ ជាថ្មីម្តងទៀត តាមរយៈលទ្ធកម្មនេះ ធនាគារជាតិកាណាដាបង្ហាញពីជំនឿចិត្តរបស់ខ្លួនមកលើធនាគារ ABA និងវិស័យធនាគារទាំងមូលនៅកម្ពុជាផងដែរ។

កំណើនដ៏រឹងមាំទូទាំងប្រតិបត្តិការធុរកិច្ចរបស់ខ្លួន ធ្វើឲ្យចំណាត់ថ្នាក់លទ្ធភាពសងរបស់ ABA ត្រូវបានដំឡើង ដោយភ្នាក់ងារវាយតម្លៃ S&P Global Ratings ដល់កម្រិត 'B+' រយៈពេលវែង ជាមួយទស្សនវិស័យ "ស្ថិរភាព" នៅក្នុងខែធ្នូ ឆ្នាំ២០១៩។ ស្របពេលជាមួយគ្នានោះដែរ ក្នុងអំឡុងពេលរបាយការណ៍ធនាគារ ABA ទទួលបានពានរង្វាន់កម្រិតខ្ពស់មួយចំនួនបីពីទស្សនាវដ្តីនៃវិស័យនេះ ដែលរួមមានពានរង្វាន់ "ធនាគារឆ្នើមជាងគេក្នុងឆ្នាំ ២០១៩ នៅកម្ពុជា" និង "ធនាគារឌីជីថលឆ្នើមជាងគេក្នុងឆ្នាំ២០១៩ នៅកម្ពុជា"។

ក្រុមប្រឹក្សាភិបាល ពិតជាមានសេចក្តីសោមនស្សជាមួយលទ្ធផលប្រតិបត្តិការដ៏រឹងមាំរបស់ធនាគារនៅក្នុងត្រីមាសចុងក្រោយនៃឆ្នាំ២០១៩ និងបន្តដើរតួនាទីយ៉ាងសកម្មក្នុងការពិនិត្យតាមដានការអនុវត្តយុទ្ធសាស្ត្ររបស់ធនាគារ ផ្អែកលើវិធីសាស្ត្រអនុវត្តល្អប្រសើរ និងស្របតាមបទដ្ឋាន។ ត្រង់នេះ ក្រុមប្រឹក្សាភិបាល មានសមត្ថភាពពេញលេញជាមួយសមាជិករបស់ខ្លួនដែលយកបទពិសោធ និងជំនាញឯកទេសនៅក្នុងវិស័យហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ចសាជីវកម្មមកអនុវត្តសម្រាប់ធនាគារ។

តាងនាមឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារប្រតិបត្តិរបស់ធនាគារ ABA សម្រាប់ការប្តេជ្ញាចិត្តយ៉ាងមុតមាំ និងភាពជាអ្នកដឹកនាំដ៏លេចធ្លោរបស់ខ្លួន។ ខ្ញុំបាទក៏សូមអនុញ្ញាតសំដែងកិច្ចថ្លែងអំណរគុណដល់ធនាគារជាតិនៃកម្ពុជា និងគណៈកម្មការមូលបត្រកម្ពុជាសម្រាប់ការបន្តផ្តល់មគ្គុទ្ទេសក៍ និងការគាំទ្រ។ ក្នុងនាមជាធនាគារពាណិជ្ជទីមួយដែលបោះផ្សាយសញ្ញាបណ្ណសាជីវកម្មក្នុងទឹកប្រាក់សរុប ៨៤,៨២១ ប៊ីលានរៀល ធនាគារ ABA សូមបង្ហាញការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះកិច្ចការអភិវឌ្ឍបន្តនៃទីផ្សារមូលបត្រ និងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអរគុណយ៉ាងជ្រាលជ្រៅដល់អតិថិជន និងភាគីពាក់ព័ន្ធសម្រាប់ការជឿទុកចិត្តមកលើធនាគារ ABA ។

ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២០

**Yves Jacquot**
ប្រធានក្រុមប្រឹក្សាភិបាល

# សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ

មានក្តីសោមនស្សរីករាយសូមផ្តល់ជូនអ្នកទាំងអស់នូវសមិទ្ធផលរបស់ធនាគារ ABA ក្នុងឆ្នាំ ២០១៩។ នេះគឺជាឆ្នាំរឹងមាំមួយទៀតដែលមានជំហានជោគជ័យ និងសមិទ្ធផលសំខាន់ៗដែលផ្លាស់ប្តូរវិជ្ជមាននូវវិស័យហិរញ្ញវត្ថុកម្ពុជា។ ធនាគារ ABA មានកំណើនរឹងមាំគ្រប់ប៉ារ៉ាម៉ែត្រចម្បងៗទាំងអស់ រួមមាន ទ្រព្យសកម្មសរុប បញ្ញើ និងកម្ចី ព្រមទាំងចំនួនអតិថិជន។

ខ្ញុំសូមអនុញ្ញាតបង្ហាញពីសមិទ្ធផលសំខាន់ៗបំផុតដែលធនាគារ ABA ទទួលបានក្នុងឆ្នាំ ២០១៩។

ដំបូង ខ្ញុំសូមចាប់ផ្តើម ដោយជម្រាបជូនអំពីការទិញយករបស់ធនាគារជាតិកាណាដានូវភាគហ៊ុនចុងក្រោយ ១០% ក្នុងធនាគារ ABA ។ ជាលទ្ធផលបានមកពីការវិនិយោគនេះ ធនាគារជាតិកាណាដាបានក្លាយជាភាគហ៊ុនិក ១០០% របស់ធនាគារ ABA។ ការទិញយកភាគហ៊ុនេះបង្ហាញពីកម្រិតទំនុកចិត្តខ្ពស់បំផុតលើធនាគារ ABA និងវិស័យហិរញ្ញវត្ថុកម្ពុជា។ ការចាក់បញ្ចូលមូលធននេះជួយជំរុញឲ្យធនាគារពង្រីកភូមិសាស្ត្រប្រតិបត្តិការ និងដាក់ឲ្យអតិថិជនកាន់តែច្រើនអាចប្រើប្រាស់ផលិតផលកម្រិតល្អបំផុតរបស់យើង។

យើងបានពង្រីកបណ្តាញសាខាថ្មីរបស់យើងបានចំនួន ១១ បន្ថែមទៀតដែលក្នុងនោះសាខាចំនួន ៩ នៅតាមខេត្ត។ ប្រាកដណាស់ យើងបន្តកែលម្អ និងពង្រីកសាខាដែលមានស្រាប់របស់យើងដែលមានប្រតិបត្តិការកើនឡើង និងត្រូវការទីកន្លែង និងគ្រឿងបរិក្ខារធនាគារស្វ័យសេវាដើម្បីបន្តបម្រើអតិថិជនដ៏មានតម្លៃរបស់យើងជាមួយសេវាកម្មកម្រិតខ្ពស់បំផុត។ នេះជាសាខាដែលមានស្រាប់ចំនួន ៦ ដែលពង្រីកម៉ោងធ្វើការ និងចូលក្នុងបញ្ជីការិយាល័យធ្វើការ ១២ ម៉ោងក្នុងមួយថ្ងៃ និង ៧ ថ្ងៃក្នុងមួយសប្តាហ៍។

ក្នុងពេលជាមួយគ្នា ការពង្រីករបស់យើងមិនកម្រិតចំពោះតែសាខាឡើយ ដោយសារយើងបានបង្កើនបណ្តាញសេវាកម្មរបស់យើងកាន់តែទំលំទូលាយដោយចាប់ដៃគូជាមួយ TrueMoney ដែលជាភាគីផ្គត់ផ្គង់សេវាទូទាត់នាំមុខគេដែលមានបណ្តាញភ្នាក់ងារច្រើនបំផុតនៅកម្ពុជា។ នៅក្នុងភាពជាដៃគូនេះ ការបង់សងកម្ចីកាន់តែងាយស្រួលសម្រាប់អតិថិជនរបស់យើងដែលរស់នៅ ឬធ្វើការនៅជិតភ្នាក់ងារ TrueMoney ជាងនៅជិតសាខា ABA នោះ។ លើសពីនេះ អតិថិជនរបស់យើងអាចធ្វើការផ្ទេរប្រាក់រវាង TrueMoney និង ABA ដោយប្រើកម្មវិធីទូរស័ព្ទគ្រប់ពេលវេលា និងគ្រប់ទីកន្លែងបាន។

សម្រាប់ឌីជីថលុបនីយកម្មនៃសេវារបស់យើង បានបន្តដំណើរជោគជ័យដោយនាំមកនូវដំណោះស្រាយនវានុវត្តន៍ និងឧបករណ៍ស្វ័យសេវាដែលអាចទុកចិត្តបានដើម្បីធ្វើឲ្យជីវិតរស់នៅរបស់ពួកគាត់កាន់តែប្រសើរ។

បណ្តាផលិតផលនៅក្នុងផ្នែករូបវន្តបុគ្គល គឺកម្មវិធី ABA Mobile មានការរីកចម្រើនគួរឲ្យកត់សម្គាល់ បើនិយាយអំពីអ្នកប្រើប្រាស់ដែលកើនឡើងពី ២៤១.០០០ កាលពីឆ្នាំមុន ដល់ ៥៥០.០០០ នៅដំណាច់ឆ្នាំ ២០១៩ ។ យើងក៏សង្កេតឃើញផងដែរថា អតិថិជនរបស់យើងកំពុងប្រើប្រាស់កម្មវិធីសេវាធនាគារតាមទូរស័ព្ទនេះយ៉ាងសកម្មបំផុត ដោយក្នុងមួយឆ្នាំចំនួនអ្នកបើកចូលមានការកើនឡើងបីដង! ដើម្បីសម្រេចបានភាគជោគជ័យនេះ ABA Mobile ត្រូវបានពង្រឹងបន្ថែម ហើយមុខងារចាំបាច់មួយចំនួនក៏ត្រូវដាក់ឲ្យប្រើប្រាស់ផងដែរ។ ជាក់ស្តែង យើងបានដាក់ឲ្យប្រើប្រាស់មុខងារផ្ទេរប្រាក់អន្តរជាតិ SWIFT និង DBP នៅក្នុងកម្មវិធីនេះ, មុខងារបើកគណនីសន្សំតាមទូរស័ព្ទ, គណនីបញ្ញើកាលកំណត់តាមទូរស័ព្ទ, និងសេវា E-Cash ជាប្រាក់រៀល ដើម្បីគាំទ្ររូបិយប័ណ្ណជាតិ។ យើងក៏បានចូលរួមជំរុញប្រព័ន្ធទូទាត់បែបឌីជីថលតាមកូដ QR របស់ ABA PAY ដោយធ្វើការបើកមុខងារទូទាត់ QR ថេរ, បន្ថែមបញ្ជីពាណិជ្ជករនៅក្នុងផ្នែកទូទាត់ ដែលជួយឲ្យអតិថិជនទទួលបានភាពបត់បែនខ្ពស់ និងងាយស្រួលក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនបានដោយផ្ទាល់ពី ABA Mobile។

PayWay ដែលជាប្រព័ន្ធទូទាត់ពាណិជ្ជកម្មអេឡិកត្រូនិកដ៏ជោគជ័យរបស់យើង ទទួលបានការពេញនិយមនៅក្នុងទីផ្សារដោយសារភាពងាយស្រួលប្រើប្រាស់, ងាយស្រួលភ្ជាប់ ឬដំឡើង, និងការបន្តគាំទ្រពីក្រុមការងាររបស់យើង។ PayWay ឥឡូវនេះកំពុងជួយដល់អាជីវកម្មរាប់រយក្នុងការបង្កើនការលក់អនឡាញ និងចំណូលរបស់ពួកគេ។ លើសពីនេះទៀត ស្ថាប័នរដ្ឋាភិបាល និងភ្នាក់ងារផ្តល់សេវាសាធារណៈ ក៏មានការជឿជាក់លើសេវានេះផងដែរ ដោយបច្ចុប្បន្ន PayWay ត្រូវបានប្រើប្រាស់ដោយ Cambodian eVisa ដើម្បីទិញសំបុត្រអនឡាញចូលទស្សនាអង្គរវត្ត ហើយរំពឹងថា នឹងត្រូវបានប្រើប្រាស់ដោយគណៈកម្មាការមូលបត្រកម្ពុជា និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ផងដែរ។ នេះ គឺជាវិភាគទានជាក់ស្តែងរបស់យើងក្នុងការជំរុញកម្ពុជា ឆ្ពោះទៅរកសង្គមទូទាត់បែបឌីជីថល។ កិច្ចខិតខំប្រឹងប្រែង និងសមិទ្ធផលរបស់ PayWay ត្រូវបានសាទរដោយទស្សនាវដ្តី Asia Marketing ដែលបានប្រសិទ្ធនាម PayWay ជាមួយពាន “Best eCommerce brand” និង “Best eCommerce platform in Cambodia” ក្នុងខែវិច្ឆិកា។

ទន្ទឹមនេះដែរ អតិថិជនរបស់យើង នៅតែត្រូវការសាច់ប្រាក់ ដើម្បីធ្វើប្រតិបត្តិការប្រចាំថ្ងៃ ដែលមានន័យថា យើងត្រូវរក្សាឧបករណ៍ស្វ័យសេវារបស់យើងឲ្យស្ថិតនៅទំនើបឈានមុខ និងមានបច្ចុប្បន្នភាព។ ឆ្នាំនេះ យើងបានពង្រឹងសាខារបស់យើង ជាមួយការបន្ថែមម៉ាស៊ីន ATM និងម៉ាស៊ីនដាក់ប្រាក់។ យើងក៏បានដាក់ឲ្យប្រើប្រាស់ឧបករណ៍ថ្មីផងដែរ គឺម៉ាស៊ីនដាក់/ដកប្រាក់ ដែលអនុញ្ញាតឲ្យអតិថិជនដាក់ប្រាក់ផង និងដកប្រាក់ផង។ ចំនួនឧបករណ៍ស្វ័យសេវាកើនឡើងស្របជាមួយនឹងផែនការបង្កើតទីតាំងស្វ័យសេវាទំនើបនៅតាមតំបន់មានប្រតិបត្តិការខ្ពស់។

ធនាគារ ABA សម្រេចឈានដល់ជំហានជោគជ័យសំខាន់ៗ ក្នុងការពង្រឹងកិច្ចការប្រឆាំងការសម្អាតប្រាក់ និង កម្មវិធីទណ្ឌកម្មតាមរយៈការអនុវត្តកម្មវិធី Coral និង Temenos។ ត្រង់នេះ ផ្នែកប្រតិបត្តិតាម និងផ្នែកបច្ចេកវិទ្យាព័ត៌មាន បានបង្ហាញការប្តេជ្ញាចិត្តខ្ពស់ កិច្ចសហការ និងសមត្ថភាពក្នុងការនាំមកនូវគុណតម្លៃដ៏ប្រសើរសម្រាប់ធនាគារ។

ក្នុងផ្នែកសាជីវកម្ម ធនាគារ ABA ជាធនាគារនាំមុខដោយដាក់ឲ្យដំណើរការមជ្ឈមណ្ឌលសេវាធនាគារអាជីវកម្ម ដើម្បីផ្តល់សេវាធនាគារប្រកបដោយគុណភាពខ្ពស់ដល់វិស័យ SME ដែលកំពុងរីកចម្រើន, ក្រុមហ៊ុនធំៗ, ក៏ដូចជាក្រុមហ៊ុនអន្តរជាតិ និងសាជីវកម្មកំពុងអភិវឌ្ឍក្នុងស្រុក។ ជាមួយការគាំទ្រពីទីប្រឹក្សាធុរកិច្ចវិជ្ជាជីវៈ ក៏ដូចជាដំណោះស្រាយនិងសេវាធនាគារសម្រាប់អាជីវកម្មដ៏ងាយស្រួលដែលយើងមានផ្តល់ជូន ធ្វើឲ្យក្រុមហ៊ុនធំៗដូចជា កូកា-កូឡា កម្ពុជា និងហុងដាកម្ពុជា សម្រេចជ្រើសយកធនាគារ ABA ធ្វើជាដៃគូផ្តល់សេវាធនាគារបង្គោលសម្រាប់ពួកគេ។

នៅក្នុងខែសីហាកន្លងទៅ ធនាគារ ABA សម្រេចបានជោគជ័យក្នុងការបោះផ្សាយសញ្ញាបណ្ណសាជីវកម្ម មានទឹកប្រាក់ ២១លានដុល្លារ និងបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា។ ត្រង់នេះ ជាថ្មីម្តងទៀត ធនាគារ ABA បានបង្ហាញស្មារតីជាអ្នកត្រួសត្រាយ ពីព្រោះសញ្ញាបណ្ណ ABA ក្លាយជាសញ្ញាបណ្ណសាជីវកម្មដំបូងដែលលក់ជូនវិនិយោគិនរូបវន្តបុគ្គលបន្ថែមពីលើវិនិយោគិន សាជីវកម្ម។ សញ្ញាបណ្ណនេះ ក៏ជាមូលបត្របំណុលដំបូងគេនៅកម្ពុជាដែលផ្តល់ជូនដោយធនាគារពាណិជ្ជ និងជាសញ្ញាបណ្ណទីមួយនៅក្នុងប្រទេសដែលទទួលបានចំណាត់ថ្នាក់ឥណទានអន្តរជាតិពី S&P។

ការទទួលស្គាល់ជាអន្តរជាតិរបស់យើងនៅឆ្នាំនេះ លើសពីពានរង្វាន់ពីរដែលខ្ញុំបានលើកឡើងនៅមុននេះ ទស្សនាវដ្តី The Banker, Euromoney, និង Global Finance សុទ្ធតែប្រសិទ្ធនាមធនាគារ ABA ថាជា “ធនាគារដ៏ឆ្នើមបំផុតនៅកម្ពុជាប្រចាំឆ្នាំ ២០១៩”! ការទទួលស្គាល់យ៉ាងទូលំទូលាយលើឧត្តមភាពរបស់យើង គឺអាស្រ័យលើយុទ្ធសាស្រ្តនៃការផ្តោតជាសំខាន់ទៅលើបច្ចេកវិទ្យា, កំណើនរឹងមាំ និងនវានុវត្តនៃសេវាធនាគារឌីជីថល និងពាណិជ្ជកម្មអេឡិកត្រូនិក។

នៅមានសមិទ្ធផលជោគជ័យដ៏ធំមួយទៀត ដែលធនាគារ ABA សម្រេចបានលើឆាកអន្តរជាតិ។ ក្នុងខែធ្នូ ទីភ្នាក់ងារ S&P Global Ratings Agency បានដំឡើងកម្រិតឥណទានរយៈពេលវែងពី “B” ដល់ “B+”។ ក្រុមអ្នកស្រាវជ្រាវ បានធ្វើការកត់សម្គាល់ពីទម្រង់ឌីជីថល និងការគ្រប់គ្រងរបស់ ABA ថាជាសមត្ថភាពប្រកួតប្រជែងខ្ពស់ ដោយមានគាំទ្រពីធនាគារជាតិកាណាដា។

សមិទ្ធផលហិរញ្ញវត្ថុរបស់យើងក្នុងឆ្នាំ ២០១៩ គួរឲ្យកត់សម្គាល់ ដោយសារយើងបន្តទទួលបានកំណើនរឹងមាំលើគ្រប់ប៉ារ៉ាម៉ែត្រចម្បងៗ៖

- ទ្រព្យសកម្មសរុបកើនឡើង ៦០% ធៀបទៅដំណាច់ឆ្នាំ ២០១៨ ហើយសម្រេចឈានដល់ ៤,៣៩ ប៊ីលានដុល្លារអាមេរិក។
- យើងបង្កើនបញ្ញើបាន ៥៥ % ហើយនៅដំណាច់ឆ្នាំ ២០១៩ ទឹកប្រាក់បញ្ញើស្មើនឹង ៣,៤០ ប៊ីលានដុល្លារអាមេរិក។
- ផល បត្រ ឥណទាន របស់យើងបានឈាន ដល់ ២,៧៦ ប៊ីលានដុល្លារអាមេរិក ដែលសម្រេចកំណើនបាន ៤៤% ពីឆ្នាំ២០១៨។
- ប្រាក់ចំណេញសុទ្ធសម្រាប់ឆ្នាំនេះ សម្រេចបាន ១២៧,៤១ លានដុល្លារអាមេរិក ស្មើនឹង ៧២% ខ្ពស់ជាងឆ្នាំមុន។
- ក្នុងរយៈពេលមួយឆ្នាំ ចំនួនអតិថិជនបានកើនឡើងជិតទ្វេរដងដល់ ៧៧៩.០០០ ធៀបនឹងឆ្នាំ ២០១៨ មានត្រឹម ៤២៦.០០០។
- កំណើនដ៏លឿននេះដោយសារតែមូលធនកើនឡើងបាន ៥៥% សរុបដល់ ៤៩៦ លានដុល្លារអាមេរិក គិតត្រឹមដំណាច់ឆ្នាំ ២០១៩ ។ ទន្ទឹមនេះដែរ ABA នៅតែទទួលផលចំណេញប្រសើរបំផុតពីអនុបាតមូលធនដែលមានអត្រា៣១,៣%។ លទ្ធផលនេះ ធ្វើឲ្យយើងក្លាយជាធនាគារដែលអនុវត្តការងារប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុតនៅក្នុងវិស័យនេះ។

ធនាគារទទួលបានលទ្ធផលទាំងនេះដោយសារកិច្ចខិតខំប្រឹងប្រែងរបស់បុគ្គលិកយើង គួបផ្សំនឹងវិធីសាស្រ្តប្រុងប្រយ័ត្ននឹងហានិភ័យ និងយុទ្ធសាស្រ្តល្អិតល្អន់។

ដោយសារយើងឈានចូលឆ្នាំ២០២០ ធនាគារ ABA មានជំហរសុវត្ថិភាពដើម្បីបន្តដំណើរជោគជ័យរបស់ខ្លួន។ ធនាគារទទួលបានកំណើនល្អជាមួយឥណទានមានគុណភាព ព្រមទាំងអនុបាតមូលធនរឹងមាំ។

ក្នុងឆ្នាំ ២០២០ យើងនឹងពង្រឹងការងាររបស់យើងក្នុងការផ្តល់នូវដំណោះស្រាយឌីជីថលជាទីទុកចិត្ត និងមានលក្ខណៈដោយឡែកតែមួយគត់។ ធនាគារ ABA ត្រូវបានគេទទួលស្គាល់ថាជាអ្នកនាំមុខទីផ្សារក្នុងដាក់ឲ្យប្រើប្រាស់ផលិតផលទំនើបផ្តោតលើអ្នកប្រើប្រាស់ ហើយយើងនឹងបន្តពង្រឹងការងារជាមួយកិច្ចខិតខំប្រឹងប្រែងពេញលេញរបស់យើង។

សម្រាប់ផ្នែកកម្ចីវិញ យើងប្រកាន់ភ្ជាប់យុទ្ធសាស្ត្ររបស់យើងក្នុងការផ្តល់ឥណទានប្រកបដោយផលិតភាព ប៉ុន្តែផ្តោតជាសំខាន់លើកម្ចីប្រតិបត្តិការដោយផ្អែកលើនិយាមអាជីវកម្មឆ្លាតវៃ និងការវិភាគទំនើបឈានមុខ។ ទន្ទឹមគ្នានេះ ភាពមិនច្បាស់លាស់នៃកិច្ចព្រមព្រៀង “អ្វីគ្រប់យ៉ាងលើកលែងតែសព្វាវុធ” (EBA) គួបផ្សំនឹងការផ្ទុះឡើងនូវមេរោគកូរ៉ូណា សេដ្ឋកិច្ចថយចុះជារួម និងលក្ខខណ្ឌអាកាសធាតុមិនអំណោយផលមួយចំនួន អាចបង្កផលប៉ះពាល់ដល់សកម្មភាពអាជីវកម្មរបស់អតិថិជនផងដែរ។ ដូច្នេះយើងនឹងខិតខំបន្ថែម ដើម្បីធ្វើតុល្យកម្មកំណើននៃមូលបត្រឥណទានឲ្យស្របតាមគោលការណ៍ទទួលអតិថិជនក្នុងកម្រិតហានិភ័យកំណត់ ខណៈដែលយើងបន្តគាំទ្រ MSME និងសហគ្រិនក្នុងស្រុក ដោយនាំមកនូវការអភិវឌ្ឍអាជីវកម្មពួកគេ។

ជារួម យើងប្តេជ្ញាចិត្តប្រើប្រាស់ឱកាសដែលភាពជោគជ័យនាពេលបច្ចុប្បន្នរបស់យើងផ្តល់ឲ្យយើង ហើយយើងជឿជាក់ថា ធនាគារ ABA មានជំហររឹងមាំក្នុងការនាំមកនូវគុណតម្លៃបន្ថែមជូនភាគហ៊ុននិករបស់យើង។

សរុបមក ខ្ញុំសូមអរគុណដល់គណៈគ្រប់គ្រងនៃធនាគារ ABA ក្នុងការកំណត់អនាគតរបស់យើង និងបុគ្គលិកជាង ៦.០០០ រូបដែលបានខិតខំប្រឹងប្រែងដើម្បីសម្រេចបានលទ្ធផលបែបនេះ។ ខ្ញុំក៏សូមអរគុណដោយស្មោះស្ម័គ្រចំពោះភាគហ៊ុនិករបស់យើង សម្រាប់ទំនុកចិត្តរបស់ពួកគេលើយុទ្ធសាស្ត្ររបស់យើង និងការគាំទ្រយ៉ាងពេញទំហឹងដល់ការរីកចម្រើនរបស់យើង។

ជាចុងក្រោយ ខ្ញុំសូមអរគុណដល់អតិថិជនទាំងអស់ សម្រាប់ទំនុកចិត្តលើធនាគារ ABA និងការរួមចំណែកដល់ភាពរីកចម្រើនរបស់ធនាគារក្នុងឆ្នាំ ២០១៩។

ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២០



**Askhat Azhikhanov**
នាយកប្រតិបត្តិ

# មាតិកា


ទស្សនៈវិស័យ, បេសកកម្ម, គុណតម្លៃ II

ព័ត៌មានហិរញ្ញវត្ថុសង្ខេប III

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប IV

សមាសភាពក្រុមប្រឹក្សាភិបាល V

សាររបស់ប្រធានក្រុមប្រឹក្សាភិបាល VI

សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ VIII

**ផ្នែកទី ១. ព័ត៌មានទូទៅពាក់ព័ន្ធបុគ្គលចុះបញ្ជីលក់មូលបត្រ** ២

- ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ៣
- ខ. លក្ខណៈនៃធុរកិច្ច ៣
- គ. ព្រឹត្តិការណ៍សំខាន់ៗរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ៤
- ឃ. ស្ថានភាពទីផ្សារ ៤
- ង. ស្ថានភាពប្រកួតប្រជែង ៥
- ច. ផែនការអនាគត ៥
- ឆ. កត្តាហានិភ័យ ៥

**ផ្នែកទី ២. ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** ៧

- ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក ៨
- ខ. រចនាសម្ព័ន្ធចំណូល ៨

**ផ្នែកទី ៣. ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម** ៩

- ក. រចនាសម្ព័ន្ធ ១០
- ខ. ក្រុមប្រឹក្សាភិបាល ១២
- គ. បុគ្គលិកជាន់ខ្ពស់ ១២

**ផ្នែកទី ៤. ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិករបស់បុគ្គលចុះបញ្ជីលក់មូលបត្រ** ១៣

- ក. ព័ត៌មានអំពីមូលបត្រ ១៤
- ខ. ថ្លៃ និងបរិមាណជួញដូរមូលបត្រ ១៤
- គ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ (ចាប់ពី ៣០%ឡើងទៅ) ១៥
- ឃ. ភាគហ៊ុនដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន (ចាប់ពី៥% ដល់តិចជាង៣០%) ១៥
- ង. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល៣(បី)ឆ្នាំចុងក្រោយ ១៥

**ផ្នែកទី ៥. របាយការណ៍សវនកម្មរបស់សវនកម្មផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង** ១៦

**ផ្នែកទី ៦. របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ** ២០

**ផ្នែកទី ៧. ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍** ២១
ក. ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ)ភាគរយឡើងទៅ នៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ ២២
ខ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់ ២២
គ. ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម ២២
ឃ. ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥(ប្រាំ) ភាគរយឡើងទៅ ២២
ង. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជីលក់ មូលបត្រក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ដែលទំនាក់ទំនង របស់បុគ្គលទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលបានធ្វើឡើងដោយបុគ្គលចុះបញ្ជីលក់មូលបត្រ ២២
ច. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល ២២
ឆ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិន ស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រ ២២
ជ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពីបុគ្គលចុះបញ្ជីលក់មូលបត្រ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ ២២

**ផ្នែកទី ៨. ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ២៣
ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ២៤
ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ២៦
គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ២៦
ឃ. ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ២៧
ង. ផលប៉ះពាល់នៃអតិផរណា ២៧
ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ២៧

ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ២៨

# ផ្នែកទី ១

## ព័ត៌មានទូទៅពាក់ព័ន្ធបុគ្គល
## ចុះបញ្ជីលក់មូលបត្រ

## ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ |
| ជាអក្សរឡាតាំង | Advanced Bank of Asia Limited |
| លេខកូដស្តង់ដារ | KH ២០០០០៩១៩៨៦ |
| ទីស្នាក់ការ | លេខ១៤១, ១៤៦, ១៤៨ និង១៤៨ ABCD វិថីព្រះសីហនុ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | (+៨៥៥) ២៣ ២២៥ ៣៣៣ |
| លេខទូរសារ | (+៨៥៥) ២៣ ២១៦ ៣៣៣ |
| គេហទំព័រ | www.ababank.com |
| អ៊ីមែល | info@ababank.com |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០១០៥៩៣ ចុះថ្ងៃទី ២៩ ធ្នូ ២០១០ |
| លេខអាជ្ញាបណ្ណអាជីវកម្ម | B១៤ ចេញដោយធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី ២២ តុលា ២០១៨ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | ១៥៥/១៩ គ.ម.ក. ចុះថ្ងៃទី០៧ សីហា ២០១៩ |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | លោក Askhat Azhikhanov |

## ខ. លក្ខណៈនៃធុរកិច្ច

ធនាគារ ABA គឺជាគ្រឹះស្ថានហិរញ្ញវត្ថុឯកជនឈានមុខមួយរបស់កម្ពុជា (សហគ្រាសឯកជន) ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៦ មានឈ្មោះថា ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់។

ឆ្លងកាត់ការអភិវឌ្ឍនិងកំណើនជាង ២០ឆ្នាំកន្លងមកនេះ ABA បានពង្រឹងជំហររបស់ខ្លួនយ៉ាងរឹងមាំក្នុងទីផ្សារ និងក្លាយជាធនាគារមួយក្នុងចំណោមធនាគារពាណិជ្ជកំពូលទាំងបី នៅក្នុងប្រទេស។ សព្វថ្ងៃនេះ ABA មានបម្រើសេវាជូនដល់បណ្តាអតិថិជនជាច្រើនដូចជា សហគ្រាសធុនតូចនិងមធ្យម, អាជីវកម្មខ្នាតតូច, និងរូបវន្តបុគ្គល។

សាខាមាន ៧៧, ម៉ាស៊ីនស្វ័យសេវា និងម៉ាស៊ីន ATM ជាង ៥៥០ ទូទាំងប្រទេស, សេវាធនាគារអនឡាញ និងធនាគារតាមទូរស័ព្ទដ៏ទំនើប ធ្វើឲ្យធនាគារ ABA អាចបម្រើអតិថិជនបានកាន់តែច្រើនឡើងៗជាមួយសេវាហិរញ្ញវត្ថុដ៏ទំនើបសម្បូរបែបនេះ។

ធនាគារ ABA គឺជាបុត្រសម្ព័ន្ធរបស់ធនាគារជាតិកាណាដា (www.nbc.ca) ដែលជាគ្រឹះស្ថានហិរញ្ញវត្ថុមួយ មានទ្រព្យសកម្មជាង ២១៤,២ ប៊ីលានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ និងមានបណ្តាញធនាគារសម្ពន្ធហិរញ្ញវត្ថុនៅទូទាំងពិភពលោក។ ដោយមានស្នាក់ការកណ្តាលស្ថិតនៅទីក្រុងម៉ុងរ៉េអាល់ ធនាគារជាតិកាណាដាបានពង្រីកសាខានៅស្ទើរតែគ្រប់ខេត្ត នៃប្រទេសជាមួយនឹងអតិថិជនក្នុងដៃ ២,៥លាននាក់។ នាមគ្រឹះស្ថានហិរញ្ញវត្ថុធំជាងគេលំដាប់ទី៦ ក្នុងប្រទេសកាណាដា និងនាំមុខគេនៅកេបិច ធនាគារជាតិកាណាដា ជាជម្រើសនៃបណ្តាសហគ្រាសធុនតូច និងមធ្យមនានានៅទីនោះ។ ក្នុងនាមជាភាគហ៊ុនិកមួយរបស់ធនាគារ ABA តាំងពីឆ្នាំ២០១៤មក ធនាគារជាតិកាណាដាបានក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុអាមេរិកខាងជើងទីមួយ ដែលឈានជើងចូលវិស័យធនាគារនៅកម្ពុជា។

## គ. ព្រឹត្តិការណ៍សំខាន់ៗរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

ចាប់តាំងពីចុះបញ្ជីពាណិជ្ជកម្មក្នុងឆ្នាំ ១៩៩៦ ធនាគារ ABA បានអភិវឌ្ឍជាច្រើនដំណាក់កាលចាប់ពីឆ្នាំ ២០១៩៖

- ធនាគារ ABA បានជោគជ័យចុះបញ្ជីសញ្ញាបណ្ណរបស់ខ្លួនដែលមានទឹកប្រាក់សរុបចំនួន ៨៤,៨ ប៊ីលានរៀលនៅក្នុងផ្សារមូលបត្រកម្ពុជា។
- ធនាគារជាតិកាណាដាបានទិញយកភាគហ៊ុន ១០% ចុងក្រោយនៅធនាគារ ABA និងបង្កើនភាគហ៊ុនកាន់កាប់របស់ខ្លួនដល់ ៩៩,៩៩%។
- ធនាគារ ABA បានបើកសាខាថ្មីចំនួន ១១ ដែលធ្វើឲ្យចំនួនសាខាសរុបមានចំនួន ៧៧។
- ភ្នាក់ងារវាយតម្លៃឥណទាន Standard & Poor's (S&P) Global Ratings បានដំឡើងកម្រិតឥណទានរបស់ធនាគារ ABA ពីកម្រិត 'B' ដល់ 'B+' ។
- ធនាគារ ABA ត្រូវបានប្រសិទ្ធនាមជាធនាគារដ៏ឆ្នើមនៅកម្ពុជាឆ្នាំ ២០១៩ ពីទស្សនាវដ្ដី The Banker។
- ទស្សនាវដ្ដីហិរញ្ញវត្ថុ Euromoney បានប្រសិទ្ធនាមធនាគារ ABA ជា "ធនាគារដ៏ឆ្នើមនៅកម្ពុជាក្នុងឆ្នាំ ២០១៩" ប្រាំមួយឆ្នាំជាប់គ្នា។
- ផលិតផលថ្មីៗជាប្រាក់រៀលចំនួនបីត្រូវបានដាក់ឲ្យដំណើរការដើម្បីលើកកម្ពស់ការប្រើប្រាស់រូបិយប័ណ្ណជាតិ៖ គណនីសន្សំតាមទូរស័ព្ទ គណនីបញ្ញើបត់បែនជាប្រាក់រៀលតាមទូរស័ព្ទ និងសេវា E-Cash ។
- ធនាគារបានបើកដំណើរការមជ្ឈមណ្ឌលធនាគារអាជីវកម្មនៅការិយាល័យកណ្ដាលរបស់ខ្លួនដើម្បីផ្ដល់សេវាធនាគារគុណភាពខ្ពស់ដល់ផ្នែក SME សាជីវកម្មអន្តរជាតិ និងក្នុងស្រុក។
- ធនាគារ ABA ទទួលបានពានរង្វាន់ "ធនាគារឆ្នើមនៅកម្ពុជា" ពីទស្សនាវដ្ដី Global Finance រយៈពេលប្រាំឆ្នាំជាប់គ្នា។
- ធនាគារបានពង្រីកការបង់សងកម្ចីតាមរយៈភាពជាដៃគូជាមួយ TrueMoney ។

## ឃ.ស្ថានភាពទីផ្សារ

យុទ្ធសាស្ត្រជាពេលបច្ចុប្បន្នរបស់ធនាគារ យើងមានបំណងក្លាយជាធនាគារជម្រើសរបស់អតិថិជននៅក្នុងទីផ្សារ និងរក្សាអតិថិជនសម្រាប់ទំនាក់ទំនងរយៈពេលវែង។ ត្រង់នេះ ធនាគារបាននឹងកំពុងផ្ដោតលើការអភិវឌ្ឍផលិតផល និងសេវាកម្មថ្មីៗដូចខាងក្រោម៖

- ផលិតផលកម្ចីងាយស្រួលសម្រាប់សហគ្រាសមីក្រូ សហគ្រាសធុនតូច និងមធ្យមដែលជាឆ្អឹងខ្នងសេដ្ឋកិច្ចកម្ពុជា។
- ការដាក់ឲ្យប្រើប្រាស់ និងការអភិវឌ្ឍបន្ថែមនូវសេវាកម្មបច្ចេកវិទ្យាទំនើប ជាពិសេសកម្មវិធីធនាគារតាមទូរស័ព្ទពេញលេញ សេវាកម្មបើកគណនី (សេវាកម្មបើកគណនីអនឡាញ សេវាកម្មបើកគណនីដល់ទីតាំងអតិថិជនផ្ទាល់) សេវា Gateway ដែលជាដំណោះស្រាយអនឡាញ PayWay និងសេវាកម្មផ្សេងៗទៀត។
- ការអភិវឌ្ឍបន្ថែមនូវផលិតផលកាត និងវិធីសាស្ត្រទូទាត់មិនប្រើប្រាក់ផ្ទាល់ដ៏ទំនើប កិច្ចសហការកាន់តែខ្លាំងជាមួយប្រព័ន្ធទូទាត់នាំមុខរបស់ពិភពលោកដើម្បីពង្រីកឱកាសនានាសម្រាប់អតិថិជន។
- ការពង្រីកសាខា (ភាគច្រើននៅខេត្ត និងស្រុក) ព្រមទាំងការពង្រីកបណ្ដាញ ATM ម៉ាស៊ីនដាក់ប្រាក់ និងម៉ាស៊ីន POS នៅទីផ្សារ
- ការកែលម្អបន្ថែមនូវគុណភាពសេវាដើម្បីបំពេញតម្រូវការរបស់អតិថិជន និងផ្ដល់ជូនអតិថិជននូវបទពិសោធល្អឥតខ្ចោះជាមួយធនាគារ ABA។
- ការអភិវឌ្ឍសំខាន់ៗនូវសេវាធនាគារសម្រាប់អតិថិជនអាជីវកម្មសម្រាប់សហគ្រាសដែលមានចំនួនកើនឡើង ក្រុមហ៊ុនធំៗ និងសាជីវកម្មអន្តរជាតិដែលបង្ហាញពីកំណើនសេដ្ឋកិច្ចកម្ពុជា។

ធនាគារបានកំណត់សកម្មភាពទីផ្សារសំខាន់ៗទាំងអស់ដើម្បីបង្កើនការយល់ដឹងរបស់ប្រជាជនពីធនាគារ ABA ជាពិសេសនៅតាមខេត្ត និងតំបន់ជនបទ ដើម្បីបង្កើតនិមិត្តសញ្ញាកាន់តែរឹងមាំ កែលម្អគុណភាពសេវាកម្មរបស់ខ្លួនស្របនឹងការអភិវឌ្ឍផលិតផល និងការលក់ថ្មីៗ។

## ង. ស្ថានភាពប្រកួតប្រជែង

ទីផ្សារកម្ពុជានៅតែមានសក្តានុពលខ្ពស់សម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុសម្រាប់កំណើន មិនត្រឹមតែនៅភ្នំពេញ ថែមទាំងនៅតាមខេត្តផងដែរ។

ការប្រកួតប្រជែងនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុមានភាពខ្ពស់ ដោយសារតែមានគ្រឹះស្ថានហិរញ្ញវត្ថុថ្មីៗ។ គិតត្រឹមដំណាច់ឆ្នាំ ២០១៩ កម្ពុជាមានធនាគារពាណិជ្ជ ៤៦ ធនាគារឯកទេស ១៥ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៨២ ប៉ុន្តែកម្រិតការដាក់បញ្ចូលសេវាធនាគារនៅទាប ហើយធនាគារតែងតែស្វែងរកលទ្ធភាពនានាដើម្បីពង្រីកបរិយាប័ន្នហិរញ្ញវត្ថុរបស់សាធារណៈ។

ដោយប្តេជ្ញាចិត្តក្លាយជាធនាគារដែលប្រជាជនកម្ពុជាទុកចិត្ត ធនាគារ ABA ទទួលបានកេរ្តិ៍ឈ្មោះជាធនាគារអាចទុកចិត្តបានដែលមានសមតុល្យរឹងមាំ និងស្ថានភាពថវិការឹងមាំ។ ជាមួយចំណុចនេះ យើងមានសមត្ថភាពផ្តល់វិសាលគមន៍ទាំងស្រុងនូវសេវាហិរញ្ញវត្ថុទំនើបដល់សហគ្រាសធុនតូច និងមធ្យម អាជីវកម្មមីក្រូ និងរូបវន្តបុគ្គល ខណៈធ្វើដំណើរជាប្រចាំដើម្បីសម្រេចគោលដៅរបស់យើងក្នុងការក្លាយជាធនាគារទីមួយរបស់កម្ពុជាដែលផ្តល់សេវាធនាគារដែលអាចទុកចិត្តបាន ងាយស្រួលប្រើប្រាស់បច្ចេកវិទ្យាទំនើប និងចូលប្រើប្រាស់បានយ៉ាងងាយស្រួល។

## ច. ផែនការអនាគត

ដោយសារសកម្មភាពហិរញ្ញវត្ថុកាន់តែស្មុគស្មាញ ហើយអតិថិជនត្រូវការភាពអាចបត់បែន និងប្រសិទ្ធភាពកាន់តែខ្ពស់ ធនាគារត្រូវតែមានសេវា និងផលិតផលនវានុវត្តន៍ជាច្រើនដើម្បីអនុញ្ញាតឲ្យអតិថិជនទទួលបានឱកាសផ្សេងៗ។ នេះជាមូលហេតុដែលធនាគារ ABA នឹងផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍបន្ថែមនូវអត្ថប្រយោជន៍សំខាន់ៗ ដូចជាសេវាធនាគារឌីជីថលទំនើប (ពីចម្ងាយ) និងគាំទ្រអតិថិជន ២៤/៧។

ចំណែកការផ្តល់កម្ចី ធនាគារប្រកាន់ខ្ជាប់នូវយុទ្ធសាស្ត្ររបស់ខ្លួនក្នុងការផ្តល់កម្ចីផលិតភាព ប៉ុន្តែផ្តោតលើកម្ចីប្រតិបត្តិការផ្អែកលើការវិភាគទំនើប និងគំរូអាជីវកម្មឆ្លាតវៃ។

## ឆ. កត្តាហានិភ័យ

### ១. ការវិភាគ

យើងសង្កេតឃើញថា មានកត្តាហានិភ័យសំខាន់ៗចំនួន២ ចំពោះសេដ្ឋកិច្ចកម្ពុជានិង ធនាគារ (ABA):

១. ហានិភ័យនៃកំណើនកម្តៅសេដ្ឋកិច្ច ការបំប៉ោងតម្លៃអចលនទ្រព្យ វិស័យសំណង់និង ទីផ្សារហិរញ្ញវត្ថុ ដែលអាចធ្វើឲ្យ តម្លៃដីធ្លាក់ចុះជាគំហុក ការខាតបង់ធំធេង ស្ទះដំណើរការនិងក្ស័យធននៅក្នុងវិស័យទាំងនោះ។

២. ហានិភ័យនៃការដាក់ទណ្ឌកម្មពីលោកខាងលិច ការលុបចោលការគាំទ្របច្ចុប្បន្នលើការនាំចូលរបស់ប្រទេសកម្ពុជាទៅ កាន់សហភាពអឺរ៉ុបនិងសហរដ្ឋអាមេរិក។ កត្តានេះធ្វើឲ្យវិស័យកសិកម្មនិងកាត់ដេរ (រោងចក្រសំលៀកបំពាក់) រងការខាត បង់ធ្ងន់ធ្ងរនិងក្ស័យធន។ ហើយកំណើនខ្ពស់នៃនិកម្មភាពអាចបង្កឲ្យមានកត្តាសង្គមនានា។

### ២. ទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់

យើងជឿជាក់ថាហានិភ័យទាំងអស់ដែលបានរៀបរាប់ខាងលើ គឺអាចគ្រប់គ្រងនិងកាត់បន្ថយបានតាមរយៈវិធីសាស្ត្រវាស់វែងគ្រប់ជ្រុងជ្រោយនានាដែលបានដាក់អនុវត្តនៅក្នុងធនាគារអេប៊ីអេ (ABA) របស់យើង។

*វិធីសាស្ត្រគ្រប់គ្រងហានិភ័យឥណទាន:*

១. យើងមានគោលនយោបាយឥណទានតឹងតែង ដែលតម្រូវឲ្យអតិថិជនមានចំណូលជាក់លាក់និងគ្រប់គ្រាន់។

២. យើងមានតម្រូវការទ្រព្យធានាតឹងតែង គឺគ្រប់កម្ចីទាំងអស់ត្រូវបានធានាដោយទ្រព្យបញ្ចាំជាទ្រព្យសកម្មដែលងាយបង្វិល ជាសាច់ប្រាក់។

៣. យើងមិនផ្តល់ហិរញ្ញវត្ថុដល់កិច្ចព្រមព្រៀងប្រថុយប្រថានលើដីធ្លី គម្រោងទើបចាប់ផ្តើម ឬក៏វិស័យណាដែលមានហានិភ័យខ្ពស់នោះទេ។

៤. យើងមិនផ្តោតសំខាន់ខ្លាំងទៅលើឧស្សាហកម្មប្រថុយប្រថានដូចជាសំណង់ ឬក៏អចលនទ្រព្យ។

៥. យើងមានចំណាត់ថ្នាក់ខ្ពស់ផ្សេងៗគ្នាចំពោះអ្នកខ្ចី គឺទំហំកម្ចីជាមធ្យមសំរាប់ប្រាក់កម្ចីតែមួយចាប់ពី៥០.០០០ដុល្លារ ដោយផ្តោតយុទ្ធសាស្ត្រកម្ចីលើអាជីវកម្មខ្នាតតូច។

៦. គុណភាពខ្ពស់នៃទំហំកម្ចីគឺអនុបាតកម្ចីខូចមានត្រឹមតែ០,៧% ដែលទាបជាង កម្រិត មធ្យមនៅលើទីផ្សារដល់ទៅ ៣ដង បង្ហាញឲ្យឃើញពីប្រសិទ្ធិភាពនៃវិធីសាស្ត្រគ្រប់គ្រងខាងលើ។

*វិធីសាស្ត្រគ្រប់គ្រងហានិភ័យសន្ទនីយភាព:*

យើងដឹងច្បាស់ថាបញ្ហាសេដ្ឋកិច្ចធ្ងន់ធ្ងរបណ្តាលឲ្យមានចលាចលក្នុងសង្គម និងភាពភ័យខ្លាចដល់អ្នកដាក់ប្រាក់បញ្ញើ។ ធនាគារបានបង្កើតនិងត្រៀមសន្ទនីយភាពបំរុងទុកសំរាប់កាត់បន្ថយហានិភ័យនៅពេលមានការដកប្រាក់បញ្ញើជាគំហុក។ ធនាគារក៏មានផែនការទុនយថាភាពយ៉ាងលម្អិតនិងផែនការសកម្មភាពសំរាប់វិបត្តិសន្ទនីយភាព ដើម្បីដោះស្រាយបញ្ហា សន្ទនីយភាពក្នុងស្ថានភាពធ្ងន់ធ្ងរណាមួយ។

ចន្លោះនេះទុកទំនេរ

# ផ្នែកទី ២

## ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក

| លទ្ធផលសម្រេចបានសំខាន់ៗ | ផែនការ | លទ្ធផលសម្រេចបាន |
|---|---|---|
| **ផ្នែកសេវាឥណទាន** | | |
| គណនីកម្ចី | ៦៦.៥១៣ | ៤៩.២៩៥ |
| ឥណទានដុលសរុប (លានរៀល) | ១១.២៦៥.០៣៧ | ៧.៣៧៣.៨០៦ |
| **ផ្នែកសេវាប្រាក់បញ្ញើ** | | |
| គណនីបញ្ញើ | ៨២៨.៦៥១ | ៤២៦.០៨៩ |
| ប្រាក់បញ្ញើសរុប (លានរៀល) | ១៣.៨៣៦.០២៥ | ៨.៧៨៧.២៩៦ |
| **ព័ត៌មានទូទៅ** | | |
| ចំនួនសាខាបើកដំណើការ | ៧៧ | ៦៦ |
| ចំនួនបុគ្គលិកសរុប | ៦.៤១០ | ៤.២១៣ |
| ចំនួនម៉ាស៊ីន អេធីអឹម | ៤១៨ | ២៧៤ |
| ចំនួនម៉ាស៊ីនទូទាត់ | ១.២១៤ | ៧៧៧ |

## ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ឆ្នាំ២០១៩ | | ឆ្នាំ២០១៨ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | % | ចំនួន (លានរៀល) | % |
| ១ | ចំណូលពីការប្រាក់ | ១.០៦៧.៩០៤ | ៨៥,៨៨ | ៧៤៤.៩២៤ | ៨៦,៦៤ |
| ២ | ចំណូលកម្រៃ និងជើងសារ | ១៦៨.៧២៨ | ១៣,៥៧ | ១០៨.៩១០ | ១២,៦៧ |
| ៣ | ចំណូលផ្សេងៗ | ៦.៩០៥ | ០,៥៦ | ៥.៩៤៩ | ០,៦៩ |
| **ចំណូលសរុប** | | **១.២៤៣.៥៣៧** | **១០០** | **៨៥៩.៧៨៣** | **១០០** |

# ផ្នែកទី ៣

## ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម

## ក. រចនាសម្ព័ន្ធ


ម្ចាស់ភាគហ៊ុន
ក្រុមប្រឹក្សាភិបាល
នាយកប្រតិបត្តិ
នាយករងប្រតិបត្តិ
គណៈកម្មាធិការអភិបាលកិច្ច
អភិបាលប្រតិបត្តិ
គណៈកម្មាធិការឥណទាន
គណៈកម្មាធិការគ្រប់គ្រងហានិភ័យ
គណៈកម្មាធិការប្រតិបត្តិតាម
គណៈកម្មាធិការសវនកម្ម
ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ
ប្រធាននាយកដ្ឋានប្រតិបត្តិតាម
ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង
នាយកហិរញ្ញវត្ថុ
នាយកដ្ឋានហិរញ្ញវត្ថុ
ផ្នែកបៀវត្ស និងពន្ធអាករ
ផ្នែករបាយការណ៍ និងសម្របសម្រួល
ផ្នែករបាយការណ៍ និងសម្របសម្រួល
នាយកដ្ឋានរតនាគារ
ផ្នែកគ្រប់គ្រងរូបិយប័ណ្ណបរទេស និងការដោះដូររតនវត្ថុ
ផ្នែកគ្រប់គ្រងសាច់ប្រាក់ជារូបវន្ត
ផ្នែកគ្រឹះស្ថានហិរញ្ញវត្ថុក្នុងស្រុក
នាយកឥណទាន
នាយកដ្ឋានឥណទានរូបវន្តបុគ្គល និង SME
នាយកដ្ឋានត្រួតពិនិត្យ និងដោះស្រាយបំណុល
នាយកដ្ឋានគ្រប់គ្រង និងប្រតិបត្តិការឥណទាន
នាយកដ្ឋានឥណទានពាណិជ្ជកម្ម
ផ្នែកគ្រប់គ្រងគុណភាពឥណទាន
នាយកដ្ឋានឥណទានអាជីវកម្មខ្នាតតូច
នាយកដ្ឋានបណ្តុះបណ្តាល និងអភិវឌ្ឍន៍ឥណទាន
នាយកដ្ឋានវាយតម្លៃហានិភ័យឥណទាន
ផ្នែកគ្រប់គ្រងទ្រព្យតម្កល់
នាយកគ្រប់គ្រងកាត និងសេវាទូទាត់អេឡិកត្រូនិក
នាយកដ្ឋានសេវាអតិថិជន
នាយកដ្ឋានគាំទ្រពាណិជ្ជករ
នាយកដ្ឋានសេវាពាណិជ្ជករ
នាយកដ្ឋានប្រព័ន្ធកាត
នាយកដ្ឋានបោះប័ណ្ណ
នាយកដ្ឋានគ្រប់គ្រងម៉ាស៊ីនទូទាត់ពាណិជ្ជករ
នាយកដ្ឋានដំណោះស្រាយបញ្ហាកាត
នាយកដ្ឋានសេវាទូទាត់អេឡិកត្រូនិក
ផ្នែកទំនាក់ទំនងភាគីផ្គត់ផ្គង់សេវាទូទាត់


នាយកបច្ចេកវិទ្យា និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ
នាយកដ្ឋានព័ត៌មានវិទ្យា
ផ្នែកគ្រប់គ្រងទិន្នន័យ និងបណ្ដាញ
នាយកដ្ឋានសន្តិសុខ
នាយកអភិវឌ្ឍន៍អាជីវកម្ម
អង្គភាពសេវាធនាគាររូបវន្តបុគ្គល
នាយកដ្ឋានអភិវឌ្ឍន៍ដំណើរការអាជីវកម្ម
នាយកដ្ឋានទំនាក់ទំនង
នាយកដ្ឋានសេវាធនាគារសម្រាប់ពាណិជ្ជកម្ម
នាយកប្រតិបត្តិការអន្តរជាតិ
នាយកដ្ឋានប្រតិបត្តិការអន្តរជាតិ
នាយកដ្ឋានអភិវឌ្ឍន៍ប្រតិបត្តិការអន្តរជាតិ
នាយកដ្ឋានប្រតិបត្តិការហិរញ្ញប្បទានពាណិជ្ជកម្ម
នាយកបច្ចេកវិទ្យាឌីជីថល
អង្គភាពបច្ចេកវិទ្យាឌីជីថល
អង្គភាពឌីជីថល និងនវានុវត្តន៍
អង្គភាពស្រាវជ្រាវ និងអភិវឌ្ឍន៍
នាយកទីផ្សារ និងលេខាធិការសាជីវកម្ម
ប្រធានអង្គភាពទីផ្សារ
ផ្នែករចនាក្រាហ្វិក
ផ្នែកបកប្រែ
នាយកដ្ឋានទីផ្សាររូបវន្ត
នាយកដ្ឋានទីផ្សារឌីជីថល
នាយកដ្ឋានទំនាក់ទំនងសាធារណៈ
ប្រធានសាខា
ប្រធានសាខាខេត្ត
ប្រធានតំបន់
នាយកដ្ឋាននីតិកម្ម
ផ្នែកដោះស្រាយវិវាទ
ផ្នែករដ្ឋបាលនីតិកម្ម
នាយកប្រតិបត្តិការសាច់ប្រាក់
ប្រធានអង្គភាពប្រតិបត្តិការសាច់ប្រាក់
នាយកដ្ឋានគាំទ្រប្រតិបត្តិការ
នាយកដ្ឋានសភាផាត់ទាត់មូលប្បទានបត្រ
នាយកដ្ឋានសេវាប្រតិបត្តិការសាច់ប្រាក់
ប្រធានអង្គភាពធនធានមនុស្ស
នាយកដ្ឋានប្រតិបត្តិការធនធានមនុស្ស
ផ្នែករដ្ឋបាលធនធានមនុស្ស
ផ្នែកទំនាក់ទំនងបុគ្គលិក
នាយកដ្ឋានលទ្ធកម្ម ទេពកោសល្យ និងជ្រើសរើសបុគ្គលិក
នាយកដ្ឋានជំនាញការធនធានមនុស្ស
ផ្នែកបណ្ដុះបណ្ដាល និងអភិវឌ្ឍន៍ធនធានមនុស្ស
នាយកដ្ឋានរដ្ឋបាល
ផ្នែកប្រតិបត្តិការរដ្ឋបាល
ផ្នែកលទ្ធកម្ម
ផ្នែកអភិវឌ្ឍន៍សាខា
ផ្នែកជួសជុល និងថែទាំ
អ្នកគ្រប់គ្រងរដ្ឋបាលតំបន់

## ខ. ក្រុមប្រឹក្សាភិបាល

សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទក្លាយជាអភិបាល | កាលបរិច្ឆេទបញ្ចប់អាណត្តិ[១] |
|---|---|---|---|---|
| ១ | លោក Yves Jacquot | ប្រធានក្រុមប្រឹក្សាភិបាល | ២៩ មីនា ២០១៦ | ២៩ មីនា ២០២២ |
| ២ | លោក Dominic Jacques | អភិបាលមិនប្រតិបត្តិ | ២៩ មីនា ២០១៦ | ២៩ មីនា ២០២២ |
| ៣ | លោក Madi Akmambet | អភិបាលប្រតិបត្តិ | ២៦ កក្កដា ២០១២ | ២៦ កក្កដា ២០២១ |
| ៤ | លោក Martin Ouellet | អភិបាលមិនប្រតិបត្តិ | ០៤ វិច្ឆកា ២០១៩ | ០៤ វិច្ឆកា ២០២២ |
| ៥ | លោក Lionel Pimpin | អភិបាលមិនប្រតិបត្តិ (លាលែង) | ៧ ឧសភា ២០១៩ | ៨ មករា ២០២០ |
| ៦ | លោក Christian St-Arnaud | អភិបាលមិនប្រតិបត្តិ (តែងតាំងថ្មី) | ៣១ ធ្នូ ២០១៩ | ៣១ ធ្នូ ២០២២ |
| ៧ | លោក Etienne Chenevier | អភិបាលឯករាជ្យ | ២៦ មិថុនា ២០១៤ | ២៦ មិថុនា ២០២០ |
| ៨ | លោក Henri Calvet | អភិបាលឯករាជ្យ | ២៩ មីនា ២០១៦ | ២៩ មីនា ២០២២ |
| ៩ | លោក Guy Quaden | អភិបាលឯករាជ្យ | ១៩ មិថុនា ២០១៩ | ១៩ មិថុនា ២០២២ |

[១] តាមខ្លឹមសារចែងក្នុងលក្ខខណ្ឌយោងនៃអភិបាលកិច្ចក្រុមប្រឹក្សាភិបាល ABA អាណត្តិនៃសមាជិកនីមួយៗរបស់ក្រុមប្រឹក្សាភិបាល ត្រូវមានរយៈពេល បី (៣)ឆ្នាំ ហើយនឹងត្រូវបន្តដោយស្វ័យប្រវត្តិ រហូតដល់ និងលុះត្រាតែមានការកំណត់ដោយការសម្រេចចិត្តពីម្ចាស់ភាគហ៊ុនរបស់ធនាគារ។

## គ. បុគ្គលិកជាន់ខ្ពស់

សមាសភាពបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះ | ភេទ | តំណែង |
|---|---|---|---|
| ១ | លោក Askhat Azhikhanov | ប្រុស | នាយកប្រតិបត្តិ |
| ២ | លោក Lee Young Ho | ប្រុស | នាយករងប្រតិបត្តិ |
| ៣ | លោក Babu Ram Gyawali | ប្រុស | នាយកហិរញ្ញវត្ថុ |
| ៤ | លោក Galymzhan Temirov | ប្រុស | នាយកបច្ចេកវិទ្យា និងអភិវឌ្ឍហេដ្ឋរចនាសម្ព័ន្ធ |
| ៥ | លោក Bibhu Pandey | ប្រុស | នាយកឥណទាន |
| ៦ | លោក Sanzhar Abdullayev | ប្រុស | នាយកគ្រប់គ្រងកាត និងសេវាកម្មទូទាត់តាមអ៊ីនធឺណិត |
| ៧ | លោក Zokhir Rasulov | ប្រុស | នាយកបច្ចេកវិទ្យាឌីជីថល |
| ៨ | លោក Zhiger Atchabarov | ប្រុស | នាយកប្រតិបត្តិការអន្តរជាតិ |
| ៩ | លោក ម៉ី ប៉ូលីន | ប្រុស | នាយកផ្នែកអភិវឌ្ឍន៍អាជីវកម្ម |
| ១០ | លោក Gibeault Roy Jonathan | ប្រុស | នាយកទីប្រឹក្សាប្រតិបត្តិតាម |
| ១១ | លោក Igor Zimarev | ប្រុស | នាយកទីផ្សារ និងលេខាធិការក្រុមហ៊ុន |

សម្គាល់៖ ព័ត៌មានលម្អិតពាក់ព័ន្ធអភិបាលកិច្ចសាជីវកម្មមានភ្ជាប់ឧបសម្ព័ន្ធ។

# ផ្នែកទី ៤

## ព័ត៌មានអំពីការផ្លាស់ប្តូរមូលបត្រ និងភាគហ៊ុនិក
## របស់បុគ្គលចុះបញ្ជីលក់មូលបត្រ

## ក. ព័ត៌មានអំពីមូលបត្រ

### ១. ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ

| | |
|---|---|
| ■ ឈ្មោះមូលបត្រកម្មសិទ្ធិ | មិនមាន |
| ■ និមិត្តសញ្ញាមូលបត្រកម្មសិទ្ធិ | មិនមាន |
| ■ ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ | មិនមាន |
| ■ តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | មិនមាន |
| ■ ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (IPO Price) | មិនមាន |
| ■ បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរលើទីផ្សារ | មិនមាន |
| ■ មូលធនូបនីយកម្មទីផ្សារ | មិនមាន |
| ■ ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត | មិនមាន |
| ■ កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ | មិនមាន |

### ២. ព័ត៌មានអំពីមូលបត្របំណុល

| ប្រភេទមូលបត្របំណុល | សញ្ញាបណ្ណសាជីវកម្ម |
|---|---|
| ប្រភេទមូលបត្របំណុល | សញ្ញាបណ្ណសាជីវកម្ម |
| សញ្ញា | ABAA២២A |
| កាលបរិច្ឆេទនៃការបោះផ្សាយ | ១៤ សីហា ២០១៩ |
| តម្លៃសរុបនៃមូលបត្របំណុល | ៨៤.៨២១.000.000 រៀល |
| តម្លៃសរុបនៃមូលបត្របំណុលដែលកំពុងចរចារ | មិនមាន |
| ឥណប្រតិទាន | ១៤ សីហា ២០២២ |
| ការវិភាគទូទាត់គូប៉ុង | ប្រចាំឆមាស |
| អត្រាគូប៉ុង (%) | ៧,៧៥% ក្នុង១ឆ្នាំ |
| តម្លៃសរុបនៃការទូទាត់គូប៉ុង | មិនមាន |
| ចំណាត់ថ្នាក់លទ្ធភាពសង (ប្រសិនមាន) | B+ |

## ខ. ថ្លៃ និងបរិមាណជួញដូរមូលបត្រ

| មូលបត្របំណុល | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ (គិតជាប្រាក់រៀល) | អតិបរមា | | | | | | មិនមាន | | | | | | ១០០.២០០ |
| | មធ្យម | | | | | | មិនមាន | | | | | | ១០០.០៥០ |
| | អប្បបរមា | | | | | | មិនមាន | | | | | | ១០០.០០០ |

| មូលបត្រ បំណុល | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| បរិមាណជួញដូរ (ឯកតា) | អតិបរមា | មិនមាន | | | | | | | | | | | ៨០ |
| | មធ្យម | មិនមាន | | | | | | | | | | | ៤៥ |
| | អប្បបរមា | មិនមាន | | | | | | | | | | | ២៣ |

## គ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ (ចាប់ពី ៣០%ឡើងទៅ)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|
| ១ | ធនាគារជាតិនៃកាណាដា | បរទេស | ២១៤.៩៩៩ | ៩៩,៩៩ |
| **សរុប** | | | **២១៤.៩៩៩** | **៩៩,៩៩** |

## ឃ.ភាគហ៊ុនដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន (ចាប់ពី៥% ដល់តិចជាង៣០%)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|
| ១ | មិនមាន | មិនមាន | មិនមាន | មិនមាន |

## ង. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល៣(បី)ឆ្នាំចុងក្រោយ

| ពិពណ៌នាលម្អិតអំពីការបែងចែងភាគលាភ | ២០១៩ | ២០១៨ | ២០១៧ |
|---|---|---|---|
| ចំណេញសុទ្ធ | | | |
| ភាគលាភជាសាច់ប្រាក់សរុប | | | |
| ភាគលាភជាមូលបត្រកម្មសិទ្ធិសរុប | | | |
| ភាគលាភផ្សេងទៀត | | មិនមាន | |
| អនុបាតនៃការបែងចែកភាគលាភ(%) | | | |
| ទិន្នផលភាគលាភ (%) | | | |
| ភាគលាភក្នុងឯកតាមូលបត្រកម្មសិទ្ធិ | | | |

# ផ្នែកទី ៥

## របាយការណ៍សវនកម្មរបស់សវនកម្ម
## ផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង

# របាយការណ៍ សវនកម្មផ្ទៃក្នុងលើប្រពន្ធ័គ្រប់គ្រងផ្ទៃក្នុងសម្រាប់ដំណាច់ឆ្នាំ ២០១៩ ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់

## I. សេចក្តីផ្តើម

សវនកម្មផ្ទៃក្នុងរបស់ធនាគារ គឺជា មុខងារវាយតម្លៃឯករាជ្យពីប្រតិបត្តិការប្រចាំថ្ងៃ ដែលត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពប្រតិបត្តិការរបស់ធនាគារចាប់ពីទស្សនវិស័យគ្រប់គ្រងផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ចសាជីវកម្ម។

សវនកម្មផ្ទៃក្នុង នឹងជួយគាំទ្រគណៈគ្រប់គ្រងជាន់ខ្ពស់ ក្នុងការបំពេញការទទួលខុសត្រូវរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តាមរយៈការផ្តល់ នូវការត្រួតពិនិត្យ ការវាយតម្លៃ និងការផ្តល់អនុសាសន៍ គ្រប់ជ្រុងជ្រោយ ទាក់ទងទៅនឹងសកម្មភាព និងប្រតិបត្តិការរបស់ធនាគារ ។

## II. វិសាលភាពនៃមុខងារសវនកម្មផ្ទៃក្នុង

វិសាលភាពចម្បងនៃសវនកម្មផ្ទៃក្នុង គឺដើម្បីត្រួតពិនិត្យ និងវាយតម្លៃលើប្រសិទ្ធភាព និងប្រសិទ្ធផលនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងគុណភាពនៃការបំពេញការងារនៃផ្នែកធុរកិច្ចរបស់ធនាគារABA ក្នុងការអនុវត្តគោលដៅធុរកិច្ច និងយុទ្ធសាស្ត្ររបស់ខ្លួន។ អំឡុងឆ្នាំនេះ នាយកដ្ឋានសវនកម្មផ្ទៃក្នុង អនុវត្តការវាស់ស្ទង់លើប្រសិទ្ធភាព និងប្រសិទ្ធផលលើផ្នែកខាងក្រោម៖

- នីតិវិធី និងបរិយាកាសរបស់កាគ្រប់គ្រងផ្ទៃក្នុង;
- ភាពគួរទុកចិត្ត និងសុក្រឹតភាពនៃព័ត៌មានហិរញ្ញវត្ថុ និងព័ត៌មានប្រតិបត្តិការ;
- គុណភាពទ្រព្យសកម្ម និងកិច្ចការពារទ្រព្យសកម្ម;
- ការប្រើប្រាស់ធនធាន;
- ប្រតិបត្តិតាមច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ នីតិវិធី និងកិច្ចព្រមព្រៀងនានា;
- ការសើបអង្កេតពិសេស រួមមានការក្លែងបន្លំខាងក្នុង/ខាងក្រៅ ឬការរំលោភសេចក្តីទុកចិត្តផ្សេងៗទៀតដែលបង្កឡើងដោយបុគ្គលិកផ្ទៃក្នុង;
- ឧបករណ៍ប្រព័ន្ធតាមដានផ្ទៃក្នុង ដូចជានីតិវិធី និងដំណើរការនៃការបែកចែកតួនាទីនិងកាតព្វកិច្ច ការគ្រប់គ្រង ទ្វេមុខការអនុញ្ញាត ការអនុម័ត ដានសវនកម្ម ការរាយការណ៍ សុវត្ថិភាពព័ត៌មាន និងផ្សេងៗ;
- ប្រព័ន្ធគ្រប់គ្រងហានិភ័យ រួមមានឧបករណ៍កំណត់ ការវាស់វែង ការត្រួតពិនិត្យ និងការកាត់បន្ថយ សញ្ញាហានិភ័យ;
- អភិបាលកិច្ចសាជីវកម្ម និងមុខងារតាមដានការប្រតិបត្តិតាម រួមមានការគោរពតាម ក្រមវិជ្ជាជីវៈ ឯកសារផ្ទៃក្នុង និងបទប្បញ្ញត្តិនានា;
- មុខងារប្រតិបត្តិតាម AML/CFT រួមមានឧបករណ៍កំណត់សញ្ញាប្រតិបត្តិការសង្ស័យ និងប្រតិបត្តិការមានហានិភ័យខ្ពស់ ការយកចិត្តទុកដាក់ស្គាល់អតិថិជន សកម្មភាពកែប្រែ ឬបញ្ចប់ទំនាក់ទំនងជាមួយអតិថិជនដែលមានហានិភ័យ រាយការណ៍ទៅនិយតករ និងគណៈគ្រប់គ្រង់ជាន់ខ្ពស់។

## III.សេចក្តីសង្ខេបនៃសកម្មភាពសវនកម្មផ្ទៃក្នុង ឆ្នាំ២០១៩

- នាយកដ្ឋានសវនកម្មផ្ទៃក្នុងអនុវត្តមុខងាររបស់ខ្លួនតាមផែនការសវនកម្មប្រចាំឆ្នាំ ដែលអនុម័តដោយគណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល។ របាយការណ៍សវនកម្មផ្ទៃក្នុងត្រូវបានបង្ហាញជូនគណៈកម្មាធិការសវនកម្មផ្ទៃក្នុងរៀងរាល់ត្រីមាស។
- ក្នុងឆ្នាំ ២០១៩ នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានធ្វើសវនកម្មលើ ២៦ សាខា និង ១៣សវនកម្ម នៅការិយាល័យកណ្តាល តាមគម្រោងសវនកម្ម។ បន្ថែមលើនេះទៀត ក្រុមការងារក៏បានធ្វើសវនកម្មមិនគ្រោងទុកចំនួន ៧២សាខាផងដែរ។ កាលវិភាគសវនកម្មប្រចាំខែ និងចំនួននៃសវនកម្មតាមគម្រោងមានដូចខាងក្រោម៖

| ល.រ | ខែ | # នៃសវនកម្មសាខា (សវនកម្មតាមផែនការ) | # នៃសវនកម្មការិយាល័យកណ្តាល(សវនកម្មតាមផែនការ) | # នៃសាខា (សវនកម្មមិនគ្រោងទុក) |
|---|---|---|---|---|
| ១ | មករា-២០១៩ | ៣ | | |
| ២ | កុម្ភៈ-២០១៩ | ៣ | ២ | ៩ |
| ៣ | មីនា-២០១៩ | ៣ | ១ | ៩ |
| ៤ | មេសា-២០១៩ | ៣ | | |
| ៥ | ឧសភា-២០១៩ | | ១ | ១៣ |
| ៦ | មិថុនា-២០១៩ | ៤ | ៣ | |
| ៧ | កក្កដា-២០១៩ | ៣ | | ១៤ |
| ៨ | សីហា-២០១៩ | | | ១០ |
| ៩ | កញ្ញា-២០១៩ | ២ | | |
| ១០ | តុលា-២០១៩ | ៣ | ៣ | ១១ |
| ១១ | វិច្ឆិកា-២០១៩ | | ៣ | ៦ |

- របាយការណ៍សម្រេចនៃសវនកម្មនីមួយៗ មានព័ត៌មានលម្អិតអំពី លទ្ធផលសវនកម្ម ហានិភ័យពាក់ព័ន្ធ និងអនុសាសន៍សវនកម្ម ដើម្បីកាត់បន្ថយហានិភ័យ ដោយភ្ជាប់ជាមួយផែនការសកម្មភាពច្បាស់លាស់ និងកាលបរិច្ឆេទកំណត់ជាក់ស្តែងដែលបានដាក់ជូនដោយដៃគូសវនកម្មនានា។
- នាយកដ្ឋានសវនកម្មផ្ទៃក្នុងកំពុងបន្តតាមដានស្ថានភាពនៃការអនុវត្តផែនការសកម្មភាពរហូតដល់គ្រប់សកម្មភាពទាំងអស់ត្រូវបានអនុវត្ត។ សកម្មភាពតាមដានស្ថានភាពនៃការអនុវត្ត នឹងត្រូវធ្វើឡើងជារៀងរាល់ខែ ជាមួយបច្ចេកទេសវាស់ស្ទង់សមស្របមុនពេលបិទផែនការសកម្មភាពនីមួយៗ។

## IV.សេចក្តីសន្និដ្ឋាន

- នាយកដ្ឋានសវនកម្មផ្ទៃក្នុង អនុវត្តយ៉ាងហ្មត់ចត់តាមនីតិវិធី សវនកម្មអាស្រ័យលើហានិភ័យ សម្រាប់រាល់ សកម្មភាពទាំងអស់ពេញមួយឆ្នាំ។ មានប្រភេទហានិភ័យជាច្រើនដែលនាយកដ្ឋានសវនកម្មផ្ទៃក្នុង បានធ្វើសវនកម្ម និងបានជូនដំណឹងក្នុងឆ្នាំ២០១៩ ដូចជា ហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ ហានិភ័យមិនប្រតិបត្តិតាម ហានិភ័យកេរ្តិ៍ឈ្មោះ ហានិភ័យសន្តិសុខ IT និងហានិភ័យផ្សេងៗទៀត។
- តាមលទ្ធផលសកម្មភាពសវនកម្មផ្ទៃក្នុង ឆ្នាំ២០១៩ ទាំងនៅសាខា និងនៅការិយាល័យកណ្តាល លទ្ធផលសវនកម្មនិងអនុសាសន៍មួយចំនួន ត្រូវបានផ្សព្វផ្សាយ។ រាល់ផែនសកម្មភាពកែប្រែ ត្រូវបានដាក់ឲ្យអនុវត្តដោយប្រធានសាខា និងប្រធាននាយកដ្ឋាននៅការិយាល័យកណ្តាលជាបន្តបន្ទាប់។
- ជាទូទៅ យើងសន្និដ្ឋានថា ប្រព័ន្ធតាមដានការត្រួតពិនិត្យផ្ទៃក្នុង អភិបាលកិច្ច និងការគ្រប់គ្រងហានិភ័យ ត្រូវបានបង្កើតឡើងគ្រប់គ្រាន់ និងត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាពនៅធនាគារ ABA ផ្អែកលើវិសាលភាពនៃសកម្មភាព និងកម្មវត្តុសវនកម្មក្នុងឆ្នាំ ២០១៩។

បានឃើញ ឯកភាព

១៧ មីនា ២០២០

Etienne Chenevier
ប្រធានគណៈកម្មាធិការសវនកម្ម

១៧ មីនា ២០២០

CheaUy Po
ប្រធានអង្គភាពសវនកម្ម

# ផ្នែកទី ៦

## របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្ម ដោយសវនករឯករាជ្យ

សូមមើលឧបសម្ពន្ធសម្រាប់របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មរួចរាល់ដោយសវនករឯករាជ្យ

# ផ្នែកទី ៧

## ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបង្ហាញពីព័ត៌មានប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធនៅ ក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ ដោយបញ្ជាក់ពីឈ្មោះ ទំនាក់ទំនងរវាងបុគ្គលចុះបញ្ជីលក់មូលបត្រ និងភាគីជាប់ពាក់ព័ន្ធ ទំហំនៃប្រតិបត្តិការ និងប្រភេទនៃផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងនោះ ដូចខាងក្រោម៖

## ក. ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ)ភាគរយឡើងទៅ នៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ

គ្មាន

## ខ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់

សូមពិនិត្យមើលឧបសម្ព័ន្ធដែលបានភ្ជាប់ជាមួយ ចំពោះរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរាល់ដូចដែលបានបង្ហាញនៅក្នុង កំណត់សម្គាល់ ៣២ សម្ព័ន្ធញាតិ។

## គ. ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម

គ្មាន

## ឃ.ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥(ប្រាំ) ភាគរយឡើងទៅ

គ្មាន

## ង. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជីលក់ មូលបត្រ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ដែលទំនាក់ទំនង របស់បុគ្គលទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលបានធ្វើឡើងដោយបុគ្គលចុះបញ្ជីលក់មូលបត្រ

គ្មាន

## ច. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល

គ្មាន

## ឆ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិន ស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រ

គ្មាន

## ជ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពីបុគ្គលចុះបញ្ជីលក់មូលបត្រ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ

សូមពិនិត្យមើលឧបសម្ព័ន្ធដែលបានភ្ជាប់ជាមួយ ចំពោះរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរាល់ដូចដែលបានបង្ហាញនៅក្នុង កំណត់សម្គាល់ ៣២ សម្ព័ន្ធញាតិ។

# ផ្នែកទី ៨

## ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងវិភាគខាងក្រោមនេះ ផ្តោតសំខាន់លើ លទ្ធផលប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ ផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹមកាលបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៩ ដែលត្រូវបានធ្វើសវនកម្មរួចរាល់ ដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRS") និងអនុលោមទៅតាមបទបញ្ញត្តិគណនេយ្យពាក់ព័ន្ធនិងគោលការណ៍ណែនាំនានាដែលចេញដោយ ធនាគារជាតិនៃកម្ពុជា។ ធនាគារធ្វើការពិភាក្សានិងវិភាគទៅលើ សមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុ និង កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់ធនាគារវឌ្ឍនៈ អាស៊ីចំកាត់។

## ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ធនគារ វឌ្ឍនៈអាស៊ីចំកាត់ មានប្រភពចំណូលធំៗចំនួន៣ គឺ ចំណូលមកពីការប្រាក់, ចំណូលកម្រៃ និងជើងសារ និងចំណូលផ្សេងៗ។

- ចំណូលមកពីការប្រាក់ រួមមាន ចំណូលការប្រាក់ពីការផ្តល់ឥណទានដល់អតិថិជន ចំណូលការប្រាក់ពីការដាក់ប្រាក់បញ្ញើនៅធនាគារ និង ចំណូលមកពីមូលប័ត្រវិនិយោគនានា។
- ចំណូលកម្រៃ និងជើងសារ រួមមាន ការសន្យាឥណទាន ចំណូលពីការផ្ទេរប្រាក់និងវេរប្រាក់ ចំណូលពីប័ណ្ណផ្សេងៗ។
- ចំណូលផ្សេងៗ រួមមាន ចំណូលពីអត្រាប្តូរប្រាក់ និង ចំណូលផ្សេងៗទៀត។

### ២. ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល | ២០១៩ | | ២០១៨ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | % | ចំនួន (លានរៀល) | % |
| ១ | ចំណូលពីការប្រាក់ | ១.០៦៧.៩០៤ | ៨៥,៨៨ | ៧៤៤.៩២៤ | ៨៦,៦៤ |
| ២ | ចំណូលកម្រៃ និងជើងសារ | ១៦៨.៧២៨ | ១៣,៥៧ | ១០៨.៩១០ | ១២,៦៧ |
| ៣ | ចំណូលផ្សេងៗ | ៦.៩០៥ | ០,៥៦ | ៥.៩៤៩ | ០,៦៩ |
| **ចំណូលសរុប** | | **១.២៤៣.៥៣៧** | **១០០** | **៨៥៩.៧៨៣** | **១០០** |

ធនាគារវឌ្ឍនៈអាស៊ីចំកាត់ ទទួលបានចំណូលដ៏ធំមកពីការប្រាក់ ដែលមានចំនួន ៨៥,៨៨% នៃប្រាក់ចំណូលសរុបក្នុងឆ្នាំ២០១៩ ដែលនៅក្នុងនោះ ៩៦%បានមកពីចំណូលការប្រាក់ពីការផ្តល់ឥណទានដល់អតិថិជន។

### ៣. ការវិភាគគម្លាតចំណេញដុល

ធនាគារ វឌ្ឍនៈអាស៊ីចំកាត់ បានរៀបចំរបាយការណ៍លទ្ធផលរបស់ខ្លួនក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីប្រាក់ចំណេញដុល។ ប៉ុន្តែ ទម្រង់របាយការណ៍នេះអាចបង្ហាញលើប្រាក់ចំណេញពីប្រតិបត្តិការ ដែលទទួលបានមកពីចំណូលសរុប ដកនឹងចំណាយប្រតិបត្តិការ ដែលនឹងត្រូវយកមកពិភាក្សានៅក្នុងចំណុច ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ។

### ៤. ការវិភាគចំនេញ/(ខាត) មុនបង់ពន្ធ

| សង្ខេបនៃរបាយការណ៍ចំណេញខាត | ២០១៩ (លានរៀល) | ២០១៨ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (%) |
|---|---|---|---|---|
| ចំណូលពីការប្រាក់ | ១.០៦៧.៩០៤ | ៧៤៤.៩២៤ | ៣២២.៩៨០ | ៤៣,៣៦ |
| ចំណាយលើការប្រាក់ | (២០៦.៧៥០) | (១៩៥.០៤៥) | (១១.៧០៥) | ៦,០០ |
| **ចំណូលមកពីការប្រាក់សុទ្ធ** | **៨៦១.១៥៤** | **៥៤៩.៨៧៩** | **៣១១.២៧៥** | **៥៦,៦១** |
| ចំណូលកម្រៃ និងជើងសារ | ១៦៨.៧២៨ | ១០៨.៩១០ | ៥៩.៨១៨ | ៥៤,៩២ |
| ចំណាយកម្រៃ និងជើងសារ | (៥៦.៣៨៦) | (៣៣.៧៩៣) | (២២.៥៩៣) | ៦៦,៨៦ |
| **ចំណូលកម្រៃ និងជើងសារសុទ្ធ** | **១១២.៣៤២** | **៧៥.១១៧** | **៣៧.២២៥** | **៤៩,៥៦** |
| ចំណូលប្រតិបត្តិការផ្សេងៗ | ៦.៩០៥ | ៥.៩៤៩ | ៩៥៦ | ១៦,០៧ |
| ចំណាយបុគ្គលិក | (២៣៤.៥៧១) | (១៤២.៧៦២) | (៩១.៨០៩) | ៦៤,៣១ |
| ចំណាយប្រតិបត្តិការ | (១០០.៥៧០) | (៦៤.៧១៣) | (៣៥.៨៥៧) | ៥៥,៤១ |
| ចំណាយរំលស់ | (៥៩.៦៦៦) | (៣៦.៧១៥) | (២២.៩៥១) | ៦២,៥១ |
| **ប្រាក់ចំណេញពីប្រតិបត្តិការ** | **៥៨៥.៥៩៤** | **៣៨៦.៧៥៥** | **១៩៨.៨៣៩** | **៥១,៤១** |
| ការខាតបង់លើឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ | (៨.៥៩៧) | (១០.០៣០) | ១.៤៣៣ | -១៤,២៩ |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **៥៧៦.៩៩៧** | **៣៧៦.៧២៥** | **២០០.២៧២** | **៥៣,១៦** |

ក្នុងឆ្នាំ២០១៩ ប្រាក់ចំណេញមុនបង់ពន្ធមានចំនួន ៥៧៦.៩៩៧ លានរៀល ដែលបានកើនឡើង ៥៣,១៦% ស្មើនឹង ២០០.២៧២ លានរៀល ប្រៀបធៀបទៅនឹង ឆ្នាំ ២០១៨ ។ ការកើនឡើងនៃប្រាក់ចំណេញនេះ គឺបណ្តាលមកពីការកើនឡើង ៤៣,៣៦% នៃចំណូលមកពីការប្រាក់ និង ចំណូលកម្រៃ និងជើងសារ ៥៤,៩២% បើប្រៀបធៀបទៅនឹង ឆ្នាំ២០១៨។

### ៥. ការវិភាគចំនេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៍ចំណេញខាត | ២០១៩ (លានរៀល) | ២០១៨ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (%) |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ៥៧៦.៩៩៧ | ៣៧៦.៧២៥ | ២០០.២៧២ | ៥៣,១៦ |
| ចំណាយពន្ធលើប្រាក់ចំណូល | (៦០.៣៣៤) | (៧៦.៦៩៦) | (១៦.៣៥២) | -២១,៣២ |
| **ប្រាក់ចំណេញសុទ្ធក្នុងគ្រា** | **៥១៦.៦៥៣** | **៣០០.០២៩** | **២១៦.៦២៤** | **៧២,២០** |

ក្នុង ឆ្នាំ២០១៩ ធនាគារវឌ្ឍនៈអាស៊ីចំកាត់ បានទទួលប្រាក់ចំណេញបន្ទាប់ពីបង់ពន្ធ ចំនួន ៥១៦.៦៥៣ លានរៀលដែលបានកើនឡើងចំនួន ៧២,២០% បើប្រៀបធៀបទៅនឹង ឆ្នាំ២០១៨ បង្ហាញអំពីការលូតលាស់យ៉ាងខ្លាំងរបស់ធនាគារ។ កត្តាមួយទៀតដែលចូលរួមចំណែកក្នុងការកើនឡើងដ៏កត់សម្គាល់នេះ គឺការលើកទឹកចិត្តពន្ធដារ ដែលបានអនុញ្ញាតពីអគ្គនាយកដ្ឋានពន្ធដារកម្ពុជា នៅថ្ងៃទី ១១ ខែមីនា ឆ្នាំ២០២០ ដោយអនុញ្ញាតឲ្យធនាគារបន្ថយពន្ធលើប្រាក់ចំណូលចំនួន ៥០% (ហាសិបភាគរយ) នៃពន្ធលើប្រាក់ចំណូលត្រូវបង់សម្រាប់ឆ្នាំ២០១៩ ដោយសារធនាគារបានចុះបញ្ជីនៅលើផ្សារមូលបត្រកម្ពុជា សម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណសាជីវកម្មនៅថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០១៩ ។ ជាលទ្ធផល ធនាគារវឌ្ឍនៈអាស៊ីចំកាត់ ទទួលបានអនុបាតចំណេញធៀបនឹងមូលធនចំនួន ៣១,២៥% និង អនុបាតចំណេញធៀបនឹងទ្រព្យសកម្មចំនួន ៣,៥៧% គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៩។

### ៦. ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៍ចំណេញខាត | ២០១៩ (លានរៀល) | ២០១៨ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (%) |
|---|---|---|---|---|
| ប្រាក់ចំណេញសុទ្ធក្នុងគ្រា | ៥១៦.៦៥៣ | ៣០០.០២៩ | ២១៦.៦២៤ | ៧២,២០ |
| ការចំណេញ/ខាតលម្អិតផ្សេងៗ | ១០.១១៤ | (៣.១៦៩) | ១៣.២៨៣ | -៤១៩,១៥ |
| **ប្រាក់ចំណេញលម្អិតសរុប** | **៥២៦.៧៦៧** | **២៩៦.៨៦០** | **២២៩.៩០៧** | **៧៧,៤៥** |

### ៧. ការវិភាគកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ គណៈគ្រប់គ្រងទទួលស្គាល់ថា ធនាគារវឌ្ឍនៈអាស៊ីចំកាត់ មិនមានកត្តាសំខាន់ៗ និងនិន្នាការសំខាន់ៗណា ដែលអាចប៉ះពាល់ដល់ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុរបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ឡើយ។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ធនាគារវឌ្ឍនៈអាស៊ីចំកាត់ គឺជាស្ថាប័នហិរញ្ញវត្ថុឯកជនដែលឈានមុខគេ ជាមួយនឹងចំណាត់ថ្នាក់ឥណទានរយៈពេលវែង និងរយៈពេលខ្លី B+ ដែលមានចក្ខុវិស័យក្លាយជាអ្នកផ្គត់ផ្គង់លេខមួយនៅក្នុងប្រទេសកម្ពុជា ដែលផ្តល់ទំនុកចិត្ត និងផ្តល់ឱ្យអតិថិជនទទួលយកនូវបទពិសោធន៍ បច្ចេកវិទ្យាទំនើបនៅក្នុងសេវាកម្មធនាគាររបស់យើង។

ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ធនាគារវឌ្ឍនៈអាស៊ីចំកាត់ បានទទួលការគាំទ្រគួរឱ្យកត់សម្គាល់ពីអតិថិជនរបស់យើង ដោយសារតែការដាក់បញ្ចូលប្រព័ន្ធឌីជីថល ប្រកបដោយភាពច្នៃប្រឌិតល្អបំផុត ដល់អតិថិជនរបស់យើង។ យើងបានពង្រឹង និង ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធធនាគាររបស់យើង ដែលអាចឱ្យយើងបម្រើដល់អតិថិជន និង ជំរុញកម្ពុជាឆ្ពោះទៅរកសង្គមឌីជីថល ដែលអាចឱ្យអតិថិជនបង់ប្រាក់សម្រាប់ទំនិញនិងសេវាកម្មដោយប្រើទូរស័ព្ទស្កេនលេខកូដQR ដែលមានសុវត្ថិភាព និងរហ័សទាន់ចិត្ត។

### ២. ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ធនាគារ វឌ្ឍនៈអាស៊ីចំកាត់ គឺជាស្ថាប័នដែលផ្តល់សេវាកម្មជូនអតិថិជន ដូចនេះហើយ ធនាគារមិនត្រូវបានទទួលផលប៉ះពាល់ចំពោះការប្រែប្រួលនៃតម្លៃរបស់វត្ថុធាត់ដើមនោះទេ។

### ៣. ការវិភាគលើពន្ធ

ធនាគារ វឌ្ឍនៈអាស៊ីចំកាត់ ស្ថិតនៅក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារនៃប្រទេសកម្ពុជា ដូច្នេះ ធនាគារមានកាតព្វកិច្ចក្នុងការបង់ពន្ធ ដោយអនុលោមទៅតាមច្បាប់ និងគោលការណ៍ណែនាំពាក់ព័ន្ធនានា ដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារនៃកម្ពុជា។ ការបង់ពន្ធរបស់ធនាគារ គឺជាការរួមចំណែកក្នុងការអភិវឌ្ឍន៍ក៏ដូចជាធ្វើឲ្យមានកំណើនសេដ្ឋកិច្ចនូវក្នុងប្រទេសកម្ពុជាផងដែរ។ សម្រាប់អនុលោមភាពល្អលើកាតព្វកិច្ចពន្ធដារ ធនាគារ ABA ទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ “មាស” ពីអគ្គនាយកដ្ឋានពន្ធដារ នៅថ្ងៃទី ២ ខែកញ្ញា ឆ្នាំ២០១៩ ដែលមានសុពលភាព ២ឆ្នាំសម្រាប់ឆ្នាំជាប់ពន្ធ ២០១៩ និង ២០២០។

### ៤. ការវិភាគលើជាតុដែលខុសពីធម្មតា និងជាតុវិសាមញ្ញ

គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៩ គណៈគ្រប់គ្រងទទួលស្គាល់ថា ធនាគារ វឌ្ឍនៈអាស៊ីចំកាត់ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និង មិនប្រក្រតីនោះទេ។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៩ គណៈគ្រប់គ្រងបានទទួលស្គាល់ថា ធនាគារវឌ្ឍនៈអាស៊ីចំកាត់ មិនមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ណាមួយនៅក្នុងការលក់និងប្រាក់ចំណូលទេ។

## ឃ.ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ធនាគារមានគោលនយោបាយមួយ ដោយមិនបង្កឲ្យមានហានិភ័យលើស្ថានភាពរូបិយប័ណ្ណបរទេសចំហច្រើននោះទេ។ ស្ថានភាពចំហនៃរូបិយបណ្ណបរទេស ត្រូវបានត្រួតពិនិត្យ និងចាត់ចែងជាប្រចាំ ជាមួយនឹងតម្រូវការប្រតិបត្តិការប្តូររូបិយបណ្ណ របស់អតិថិជន និងតម្រូវការគ្រប់គ្រងចាត់ចែងទ្រព្យសកម្ម និងអកម្មរបស់ធនាគារ ដោយលៃយ៉ាងណា ធានាបាននូវនិរន្តភាពនៃប្រាក់ចំណេញជូនដល់ធនាគារ។

## ង. ផលប៉ះពាល់នៃអតិផរណា

អត្រាអតិផរណានៅកម្ពុជាក្នុងឆ្នាំ ២០១៩ មានកម្រិតត្រឹម ១,៩% យោងតាមសេចក្តីជូនដំណឹងរបស់ធនាគារជាតិនៃកម្ពុជា នៅក្នុងពិធីបើកកិច្ចប្រជុំប្រចាំឆ្នាំនៅថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០២០ ។ ទោះជាយ៉ាងណាក៏ដោយអត្រាអតិផរណានេះមិនបានជះឥទ្ធិពល ដល់ប្រាក់ចំណេញហិរញ្ញវត្ថុរបស់ធនាគារនោះទេ ដោយសារតែធនាគារមិនបានកែប្រែអត្រាការប្រាក់ផ្អែកលើអតិផរណា។ យើងធ្វើការកែតម្រូវអត្រាការប្រាក់ដោយផ្អែកលើបរិយាកាសប្រកួតប្រជែងនៅក្នុងទីផ្សារ ដោយរក្សាតម្លៃរយៈពេលយូរជូនភាគហ៊ុនិក។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលបានមានគោលនយោបាយរូបិយវត្ថុ ដែលសំដៅរក្សាស្ថិរភាពថ្លៃ ដើម្បីរួមចំណែកជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ។ បច្ចុប្បន្ន ឧបករណ៍គោលនយោបាយ រូបិយវត្ថុដែលត្រូវបានប្រើប្រាស់ដើម្បីរក្សាស្ថិរភាពថ្លៃ គឺការដាក់អត្រាប្រាក់បម្រុងកាតព្វកិច្ច និង ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាកំពុងអភិវឌ្ឍ ឧបករណ៍គោលនយោបាយរូបិយវត្ថុបន្ថែម ដើម្បីពង្រឹងប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ តាមរយៈការចេញផ្សាយមូលបត្រអាចជួញដូរបាន ការអភិវឌ្ឍន៍ទីផ្សារអន្តរធនាគារនិងទីផ្សារ រូបិយវត្ថុ និងការពង្រឹងការប្រើប្រាស់ប្រាក់រៀល ។ល។ ដែលនឹងជួយធ្វើឲ្យធនាគារកាន់តែមានជម្រើសច្រើនថែមទៀតក្នុងការស្វែងរកប្រភពទុន សម្រាប់គាំទ្រកំណើនឥណទានជាប្រាក់រៀល និងជួយធ្វើឲ្យធនាគារអាចខ្ចី ឬវិនិយោគសាច់ប្រាក់ជាមួយគ្នាបានក្នុងរយៈពេលខ្លីក្នុងទីផ្សារអន្តរធនាគារ។

ចន្លោះនេះទុកទំនេរ

## ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

**បានអាន និងឯកភាព**
ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០



លោក **Madi Akmambet**
អភិបាលប្រតិបត្តិ

ជ. លោក **Yves Jacquot**
ប្រធានក្រុមប្រឹក្សាភិបាល



លោក **Madi Akmambet**
អភិបាលប្រតិបត្តិ

ជ. លោក **Dominic Jacques**
អភិបាលមិនប្រតិបត្តិ



លោក **Madi Akmambet**
អភិបាលប្រតិបត្តិ

ជ. លោក **Martin Ouellet**
អភិបាលមិនប្រតិបត្តិ



លោក **Madi Akmambet**
អភិបាលប្រតិបត្តិ

ជ. លោក **Christian St-Arnaud**
អភិបាលមិនប្រតិបត្តិ



លោក **Madi Akmambet**
អភិបាលប្រតិបត្តិ

ជ. លោក **Guy Quaden**
អភិបាលឯករាជ្យ



លោក **Madi Akmambet**
អភិបាលប្រតិបត្តិ

ជ. លោក **Henri Calvet**
អភិបាលឯករាជ្យ



លោក **Madi Akmambet**
អភិបាលប្រតិបត្តិ

ជ. លោក **Etienne Chenevier**
អភិបាលឯករាជ្យ



លោក **Madi Akmambet**
អភិបាលប្រតិបត្តិ

ABA BANK

NATIONAL BANK OF CANADA GROUP

លេខ១៤១, ១៤៦, ១៤៨ និង១៤៨ ABCD វិថីព្រះសីហនុ សង្កាត់បឹងកេងកង១
ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

(+៨៥៥) ២៣ ២២៥ ៣៣៣ | ទូរសារ: (+៨៥៥) ២៣ ២១៦ ៣៣៣
info@ababank.com | www.ababank.com